ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លី ឃុំត្រពាំងរូង

## ឆ្នាំ ២០០៩-២០២២

## ស្រុក កោះកុង ខេត្ត កោះកុង



រៀបចំដោយៈ គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

គាំទ្រដោយៈ ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

# មាតិកា


**អារម្ភកថា** ..... 1

**សេចក្ដីផ្ដើម** ..... 2

**ជំពូក១** ..... 4

**ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់** ..... 4

**១.១ ស្ថានភាពទូទៅ** ..... 4

១.១.១ ទីតាំងរដ្ឋបាល ..... 4

១.១.២ ប្រជាសាស្ត្រ ..... 5

១.១.៣ ភាពគ្មានដីធ្លី ..... 6

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ..... 7

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ..... 8

១.១.៦ ស្ថានភាពសុខាភិបាល ..... 9

១.១.៦.១ ផ្នែកសុខាភិបាល ..... 9

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ..... 10

**១.២ ស្ថានភាពភូមិសាស្ត្រ** ..... 11

១.២.១ ទីតាំងភូមិសាស្ត្រ ..... 11

១.២.២ អាកាសធាតុ ..... 11

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ..... 12

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ..... 13

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ..... 13

១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី ..... 14

១,៣,៣ ផលិតកម្មកសិកម្ម ..... 16

១,៣,៤ ធនធានធម្មជាតិ ..... 20

១.៣.៤.១ ធនធានព្រៃឈើ ..... 20

១.៣.៤.២ ធនធានជលផល ..... 20

១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល 21

១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ 21

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល 21

១.៤.៣ ឱកាស ឧបសគ្គ 22

ជំពូក២ 22

ការវិភាគពីតម្រូវការសំរាប់អនាគត ឧបសគ្គ និង សក្តានុពល 22

២.១ តំបន់រសើប 22

២.២ ការប្រឈម/ឧបសគ្គ 22

២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្តឃុំត្រពាំងរូង 23

២.៤ តម្រូវការសំរាប់អនាគត 24

២.៤.១ ប្រជាសាស្រ្ត 24

២.៤.១.១ អត្រាកំណើន 24

២.៤.១.២ ការធ្វើចំណោលប្រជាសាស្រ្ត 25

២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន 26

២.៤.៣ តម្រូវការដីកសិកម្ម 26

២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ 28

២.៤.៥ តម្រូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម 28

២.៤.៥.១ តម្រូវការសាលារៀន 29

២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត 30

២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា 31

២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព 31

ជំពូក ៣ 32

ផែនការប្រើប្រាស់ដីអនាគត 32

៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី 32

៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល 32

៣.១.២ តម្រូវការដីតាមប្រភេទ.......... 33

**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់**.......... 35

៣.២.១ ការវិភាគអន្តរអំពើ.......... 35

៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត .......... 36

៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី.......... 36

៣.២.៣.១ដីលំនៅដ្ឋាន ( បញ្ញត្តិ គោលការណ៍ នៃ ការប្រើប្រាស់ដី) .......... 37

៣.២.៣.២ ការប្រើប្រាស់ទឹក និង ប្រព័ន្ធស្រោចស្រព .......... 40

៣.២.៣.៣ ការប្រើប្រាស់ផ្លូវថ្នល់ .......... 40

៣.២.៣.៤ ទីតាំងផ្លូវក្រាលគ្រួសក្រហម.......... 40

៣.២.៣.៥ ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់ .......... 40

៣.២.៣.៦ ការប្រើប្រាស់ដីក្នុងកិច្ចការពារធម្មជាតិ និង បរិស្ថាន.......... 41

**ឧបសម្ពន្ធ័១ : ការពិពណ៌នាអំពី ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ..........42

**ឧបសម្ពន្ធ័២ : ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន**..........48

**ឧបសម្ពន្ធ័៣ : បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី(បញ្ហា/មូលហេតុ/ដំណោះស្រាយ)**..........50

**ឧបសម្ពន្ធ័៤ : ក្របខ័ណ្ឌអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីថ្មីអនាគត** ..........57

**ឧបសម្ពន្ធ័៥ : បញ្ជីគម្រោង ឬសកម្មភាពសំខាន់ៗរបស់ឃុំក្នុងរយៈពេល ១៥ ឆ្នាំ** ..........60

**ឧបសម្ព័ន្ធ៦ : ផែនទីប្រើប្រាស់ដីលំអិតក្នុងឃុំ**

**ឧបសម្ព័ន្ធ៧ : ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំ**

**ឧបសម្ព័ន្ធ៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគតក្នុងឃុំឆ្នាំ ២០០៩-២០២២**

# អារម្ភកថា

ឯកសារស្ដីអំពីផែនការប្រើប្រាស់ដីនៅក្នុងឃុំត្រពាំងរូងឆ្នាំ ២០០៩-២០២២ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ និងមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ចូលរួមពីអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកកោះកុង(D.LUP)សហការចូលរួមពីអ្នកសម្របសម្រួលពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីខេត្តកោះកុង(P.LUP) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី(Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZAid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ។

ការរៀបចំចងក្រងជាសៀវភៅផែនការនេះឡើង ដើម្បីជាត្រីវិស័យក្នុងការអភិវឌ្ឍន៍ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ការប្រើប្រាស់ដីឱ្យចំទិសដៅដែលមានការផ្សារភ្ជាប់ទៅនឹងផែនការជាតិ អភិវឌ្ឍន៍សង្គមកិច្ច និងសេដ្ឋកិច្ចផងដែរ និងដើម្បីចូលរួមចំណែកលើកកំពស់ជីវភាព ធានាសន្តិសុខស្បៀងព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋជាពិសេសនៅតាមតំបន់ជនបទដែលជីវភាពស្ទើរតែទាំងស្រុងពឹងផ្អែកលើធនធានធម្មជាតិ ។ ផែនការប្រើប្រាស់ដីធ្លីនេះមានសារៈសំខាន់ណាស់ក្នុងការជួយចង្អុលបង្ហាញទិសដៅដល់ការអភិវឌ្ឍន៍ឃុំឱ្យឆ្លើយតបទៅនឹងតំរូវការពិតប្រាកដរបស់ប្រជាពលរដ្ឋដើម្បីបង្កើនកំរិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ។

ក្រុមប្រឹក្សាឃុំត្រពាំងរូងសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការDANIDA/DFID-NZAid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានផ្ដល់ថវិកាជំនួយ សំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះចាប់តាំងពីការចាប់ផ្ដើមរហូតដល់ទីបញ្ចប់ ។ ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការនេះក៏អាចនឹងមិនទទួលបានភាពជោគជ័យផងដែរដរាបណាគ្មានការចូលរួមពីមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្មខេត្ត និងមន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំត្រពាំងរូងក៏មិនអាចបំភ្លេចបានដែរ នូវការជួយឧបត្ថម្ភគាំទ្របង្ហាត់បង្ហាញទាំងទ្រឹស្ដី និងបច្ចេកទេសផ្ទាល់លើការរៀបចំផែនការប្រើប្រាស់ដីធ្លី ពីក្រុមអ្នកសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លី ថ្នាក់ស្រុក ( D-LUP ) ថ្នាក់ខេត្ត( P-LUP ) និង ក្រុមការងារថ្នាក់ជាតិ ( N-LUP ) របស់សមាសភាគរៀបចំដែនដី ។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្ដេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពីស្ថានភាព និងតំរូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីដែលរាំងស្ទះដល់ដំណើការអភិវឌ្ឍន៍ឃុំត្រពាំងរូង ហើយនឹងបង្ហាញនូវទឹកចិត្តសប្បុរសធម៌ដ៏ថ្លៃថ្លាតាមរយៈការចូលរួមផ្ដលនូវសម្ភារៈ និងថវិកាសម្រាប់គាំទ្រការអនុវត្តផែនការប្រើប្រាស់ដីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការរបស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

ធ្វើនៅត្រពាំងរូង, ថ្ងៃទី..២២..ខែ...៥.......ឆ្នាំ ២០០៩

**មេឃុំ**

ភាយ_ស៊ុយ

# សេចក្តីផ្តើម

បច្ចុប្បន្ននេះមានគំរោងអភិវឌ្ឍន៍ជាច្រើនកំពុងដំណើរការក្នុងគោលបំណងផ្សេងៗគ្នា ដែលគំរោងអភិវឌ្ឍន៍ខ្លះពុំបានគិតដល់ការអភិរក្ស និង ការធ្វើសមាហរណកម្មផែនការដូចក្រុមប្រឹក្សាគោលនយោបាយដីធ្លី បង្ហាញយ៉ាងច្បាស់អំពីកង្វះខាតក្នុងការធ្វើសមាហរណកម្ម នៃការកសាងផែនការប្រើប្រាស់ដីធ្លី និង ការគ្រប់គ្រងធនធានធម្មជាតិ ដែលនាំឱ្យមានកើតឡើងនូវបញ្ហាយ៉ាងច្រើនដូចជា : ការទន្ទ្រានលើតំបន់ការពារ ការសាងសង់លើទីតាំងដែលមិនសមស្រប ការកាប់ឈើខុសច្បាប់ ការរំលោភយកដី និង លុបចោលនូវសិទ្ធិប្រើប្រាស់ធនធានធម្មជាតិសំរាប់ការចិញ្ចឹមជីវិត ។

បញ្ហានេះប៉ះពាល់ដល់ចីរភាព នៃការធ្វើអាជីវកម្មព្រៃឈើ បូមខ្សាច់ និង ការប្រើប្រាស់ទឹកក្នុងគោលដៅសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះក៏ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ទេសចរធម្មជាតិ និង ការរីកចំរើននៃទីក្រុងផងដែរ ។

ការកសាងផែនការប្រើប្រាស់ដីធ្លី បានចាត់ទុកជាមូលដ្ឋានគតិយុត្តិមួយសំរាប់អភិវឌ្ឍន៍ និង ការប្រើប្រាស់ដីធ្លីក្នុងគោលបំណងបំរើផលប្រយោជន៍សាធារណៈ ។

ប្រពន្ធ័នៃការរៀបចំផែនការដ៏មានប្រសិទ្ធិភាពជាមធ្យោបាយដ៏ល្អបំផុតដើម្បីឆ្លើយតបទៅនឹងតំរូវការអភិវឌ្ឍន៍ និង កិច្ចការពារបរិស្ថាន ។ ដូច្នេះផែនការនេះគឺជាគន្លឹះមួយដែលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលដែលជួយដល់ការអភិវឌ្ឍន៍ចាំបាច់មួយចំនួននៅលើទីតាំងដ៏សមស្រប និង មិនធ្វើឱ្យបាត់បង់នូវធនធានធម្មជាតិសំរាប់កូនចៅជំនាន់ក្រោយ ។ ផែនការនេះនឹងបង្កើតឱ្យមានក្របខ័ណ្ឌច្បាស់លាស់ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លី និង ការវិនិយោគទូទៅផងដែរ ។ តួយ៉ាងឃុំត្រពាំងរូងជាឃុំមួយក្នុងចំណោមឃុំទាំង ៤ របស់ស្រុកកោះកុង ខេត្តកោះកុង ដែលសំបូរទៅដោយព្រៃឈើ និង ភ្នំ ហើយឃុំនេះត្រូវបានជ្រើសរើសជាឃុំគោលដៅសំរាប់ការអនុវត្តន៍រៀបចំផែនការប្រើប្រាស់ដីធ្លី ។ ដោយមានការព្រួយបារម្ភអំពីការអភិវឌ្ឍន៍ខុស ទិសដៅមិនមានចីរភាព និង អាចបណ្តាលឱ្យមានការវិនាសដល់ធនធានធម្មជាតិ បរិស្ថានកាន់តែខ្លាំង និង បង្កឱ្យមានផលប៉ះពាល់ដល់កំរិតជីវភាពរស់នៅ និង ភាពសុខដុមរមនារបស់ប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូងនេះទាំងមូល ។ គោលបំណងចំបងនៃផែនការប្រើប្រាស់ដីធ្លីនៅឃុំត្រពាំងរូងនេះគឺដើម្បីគាំទ្រដល់ដំណើរការកសាងផែនការ អភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំ-សង្កាត់គាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ប្រកបដោយនិរន្តរភាព និង សមធម៌រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជួយធ្វើឱ្យសំរេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីធ្លីក្នុងមូលដ្ឋានឃុំសង្កាត់ស្របតាមស្ថានភាពដីជាក់ស្តែង និង សក្តានុពលធម្មជាតិនៃដី ឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ជួយការពារធនធានដី ធនធានធម្មជាតិផ្សេងៗទៀត មិនឱ្យបាត់បង់គុណភាព និង មិនឱ្យប្រើប្រាស់ខុសទិសដៅ រួមចំណែកក្នុងការកំណត់ និង គ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំឱ្យបានល្អ ស្វែងរកការគាំទ្របច្ចេកទេសបន្ថែមពីស្ថាប័នអង្គភាពនានា និង ពីផ្នែកឯកជនផងដែរ និង ជួយដល់ក្រុមប្រឹក្សាឃុំផ្ទាល់ក៏ដូចជា អ្នកពាក់ពន្ធ័ទាំងអស់

នៅថ្នាក់ក្រោមជាតិក្នុងការរួមចំណែកដល់ការរៀបចំផែនការគ្រប់គ្រង និង ប្រើប្រាស់ ធនធានដី និង ធនធានធម្មជាតិនៅក្នុងឃុំ ការរៀបចំអភិវឌ្ឍន៍ឃុំទាំងមូលទាំងដីរដ្ឋ ទាំងដីឯកជនឱ្យចំទិសដៅប្រកបដោយប្រសិទ្ធិភាព និងកាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ដីធ្លីឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែង ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ គោលនយោបាយវិមជ្ឈការ និង សហវិមជ្ឈការសំដៅពង្រឹងអភិបាលកិច្ចល្អ របស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ចក៏រិតជីវភាពរស់នៅ និង សុខដុមរមនារបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

ដូច្នេះក្រោយពីមានផែនការប្រើប្រាស់ដីធ្លីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិជាពិសេសអាជ្ញាធរដែនដីនឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀចំបញ្ចូលផែនការប្រើប្រាស់ដីធ្លីរបស់គាត់នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និង អនុម័តនៅថ្នាក់ខេត្តដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមធ្វើការសំរេច ។

# ជំពូក១

# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅ

-ប្រវត្តិឃុំៈ កាលពីអតីតកាលនៅក្នុងឃុំនេះមានត្រពាំងធំមួយដែលមានបណ្តោយប្រមាណ ៣៥០ ម៉ែត្រ និងមានទទឹងប្រមាណ ១០០ ម៉ែត្រ ហើយនៅមាត់ត្រពាំងផ្នែកខាងលិចមានផ្ទាំងថ្មធំៗ និងមានរូងផង រូងនេះតាមពាក្យតំណាលតៗគ្នាថាជារូងខ្លា និង មានកូនមានចៅនៅទីនោះដែរ ។ ប្រជាជននៅក្នុងភូមិហៅកន្លែងត្រពាំងនោះថា "ត្រពាំងរូង" លុះដល់សម័យសង្គមរាស្ត្រនិយមបានបង្កើតភូមិ និង ឃុំ ឈ្មោះភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង រហូតមកដល់សព្វថ្ងៃនេះ ។

-ឃុំត្រពាំងរូងគឺជាឃុំមួយក្នុងចំណោមឃុំទាំងបួនរបស់ស្រុកកោះកុង ឃុំនេះស្ថិតនៅក្នុងទីរួមស្រុកកោះកុង មានប្រជាពលរដ្ឋរស់នៅចំនួន ៥០៧ គ្រួសារ មនុស្សសរុប ២,១៧០ នាក់ ។ ឃុំនេះមានផ្លូវជាតិលេខ ៤៨ ឆ្លងកាត់ និងមានចំងាយផ្លូវពីឃុំទៅទីរួមខេត្តប្រមាណ ៦២ គីឡូម៉ែត្រ ។ ការប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋភាគច្រើនធ្វើស្រែចំការ និង នេសាទ ។ ប៉ុន្តែបច្ចុប្បន្នការបង្កបង្កើនផលពុំសូវទទួលបានជោគជ័យដោយសារខ្វះឧបករណ៍ ខ្វះកំលាំងអូសទាញ និង ខ្វះជំនាញបច្ចេកទេស ការធ្វើនេសាទពុំសូវទទួលផល ព្រោះធនធានជលផលថយចុះ ដីស្រែមួយចំនួនធំត្រូវស្ថិតនៅទំនេរគ្មានលទ្ធភាពកែឆ្នៃ និង ស្តារឡើងវិញ ។ ការដាំដុះការផលិតកសិផលផ្សេងៗពិបាករកទីផ្សារ ការចិញ្ចឹមសត្វជួបប្រទះនូវជំងឺបំផ្លាញ ។ ប្រជាពលរដ្ឋភាគច្រើនមានបញ្ហាសុខភាពដោយសារខ្វះទឹកស្អាត និង ធ្វើការងារហួសកំលាំង ប្រជាពលរដ្ឋមួយចំនួនអវិជ្ជា ។ បញ្ហាទាំងនេះធ្វើឱ្យជីវភាពរស់នៅរបស់គាត់មានការលំបាកគឺចំណូលប្រចាំថ្ងៃត្រឹមតែ ៨,០០០ ៛ ។ ការចំណាយ និង ចំណូលមិនតុល្យភាពនឹងគ្នា ធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនតូចចងការប្រាក់ពីឯកជនគឺសេវាគិត ១០ ភាគរយក្នុង ០១ ខែ ខ្លះទៀតចងការពីធនាគារគឺសេវាគិត ៣ ភាគរយក្នុង ០១ ខែ ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | កោះកុង | |
| ស្រុក/ក្រុង | កោះកុង | |
| ឃុំ/សង្កាត់ | ឈ្មោះ ត្រពាំងរូង | លេខកូដ: ០៩០៣០៤ |
| ចំនួនភូមិ | ៤ ភូមិ ក្នុងនោះមាន :ត្រពាំងរូង ,ដីទំនាប , ព្រែកអង្គុញ , កោះកុងក្នុង | |

ឃុំត្រពាំងរូងមានផ្ទៃដីចំនួន ៩០,៦៩៣.៩៤ ហិកតា ស្មើ ៩០៦.៩៤ គីឡូម៉ែត្រការ៉េ ចែកចេញជា ៤ ភូមិ (ក្នុងនោះ ២ ភូមិស្ថិតក្នុង តំបន់ការពាររបស់អង្គការការពារសត្វព្រៃ) ឃុំនេះមានព្រំប្រទល់ខាងជើងជាប់ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខាងត្បូងជាប់ ឃុំជ្រោយប្រស់ ខាងកើតជាប់ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរខាងលិចជាប់ឃុំតាតៃក្រោម ។ បើគិតទៅទីរួមខេត្តកោះកុងមានចំងាយ ៦២ គីឡូម៉ែត្រ ធ្វើដំណើរតាមផ្លូវជាតិលេខ ៤៨ ។




## ១.១.២ ប្រជាសាស្ត្រ

ឃុំត្រពាំងរូងមានប្រជាជនសរុបចំនួន ៥០៧ គ្រួសារ ប្រជាជនចំនួន ២,១៧០ នាក់ ក្នុងនោះស្ត្រី ១,០៦២ នាក់ មានដង់ស៊ីតេ ២ នាក់ក្នុង១គីឡូម៉ែត្រក្រឡា។ របាយប្រជាជននៅឃុំត្រពាំងរូងក្រៅពីជនជាតិខ្មែរនៅមានជនជាតិចាមរស់នៅលាយលំជាមួយ ។ ជាទូទៅប្រជាជនភាគច្រើនកាន់សាសនាព្រះពុទ្ធ និង ជនជាតិចាមកាន់សាសនាឥស្លាម មានតិចតួចប៉ុណ្ណោះ ។

តារាងស្ថិតិប្រជាជនឃុំត្រពាំងរូង ឆ្នាំ២០០៨ តាមក្រុមអាយុ

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ១១៥ | ១១៩ | ២៣៤ | |
| អាយុ ០៥ឆ្នាំ | ៣៩ | ៣៣ | ៧២ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ១៤០ | ១៥៦ | ២៩៦ | អាយុចូលរៀនបឋមសិក្សា |

| | | | | |
|---|---|---|---|---|
| អាយុពី ១២-១៤ឆ្នាំ | ៩២ | ៨៦ | ១៧៨ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ៩៥ | ៨២ | ១៧៧ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ១៤៨ | ១៣៦ | ២៨៤ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ៤៣៦ | ៤១០ | ៨៤៦ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៤៣ | ៤០ | ៨៣ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | ១,១០៨ | ១,០៦២ | ២,១៧០ | |
| ចំនួនគ្រួសារសរុប | **៥០៧** | | | |

### ១.១.៣ ភាពគ្មានដីធ្លី

- គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន ៣១ គ្រួសារ គ្រួសារប្រភេទនេះបច្ចុប្បន្នត្រូវបានប្រកបរបរដោយការស៊ីឈ្នួលដកស្ទូង ច្រូតស្រូវ និងខែប្រាំងចេញទៅរករបរនេសាទ និងអនុផលព្រៃឈើ ។
- គ្រួសារមានដីស្រែតិចជាង ០១ ហិកតា: ៤២ គ្រួសារ គ្រួសារទាំងនេះក៏ត្រូវរកចំណូល បន្ថែមទើបអាចហូបចុកគ្រប់គ្រាន់ ដែលក្នុងនោះពួកគាត់ត្រូវស៊ីឈ្នួលដកស្ទូងធ្វើនេសាទ និង រកអនុផលព្រៃឈើបន្ថែមដើម្បីបំពេញការទិញអង្ករហូបនៅរដូវវស្សា គ្រួសារប្រភេទនេះមានអ្នកខ្លះមានគោ ក្របី ខ្លះមានគោយន្តភ្ជួរដីផងដែរ ។
- ចំនួនគ្រួសារដែលមានផ្ទះនៅលើដីក្នុងតំបន់ការពារចំនួនៈ ២៤៥ គ្រួសារ ហើយគ្រួសារប្រភេទនេះ មានដីស្រែនៅក្បែរភូមិ ម្យ៉ាងដីលំនៅដ្ឋានរបស់ពួកគាត់មានទីតាំងភូមិចាស់ពីសង្គមចាស់មកម្ល៉េះដូចជាភូមិព្រៃកអង្គុញ ភូមិកោះកុងក្នុង ឯទីផ្សេងទៀតដូចជា វាលតាភូ ខ្មែរលើ ចំណុចវាលស្បូវ (ស្ថិតនៅក្នុងភូមិត្រពាំងរូង) លំនៅដ្ឋានរបស់ពួកគាត់ខ្លះបានរស់នៅចាប់តាំងពីឆ្នាំ ១៩៩១ ខ្លះទៀតនៅអំឡុងឆ្នាំ ១៩៩៩ (ចំណុចវាលស្បូវ) ។ គ្រួសារប្រភេទនេះអ្នកខ្លះ មានដីចំការចាស់ និង ថ្មីមួយគ្រួសារអាចមាន ១ ហិកតា ទៅ ២ ហិកតា ។

<u>តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់</u>

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ៣១ | ៣១.៣១% | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ៤២ | ៤២.៤២% | |
| ៣ | មានដីស្រែនៅឆ្ងាយពីភូមិ ហើយមិនមានដីលំនៅដ្ឋានផ្ទាល់ខ្លួន | ១៥៤ | | |



### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូងប្រមាណ ១៩.៥៣ % មានមុខរបរធ្វើស្រែចំការ ដោយពឹងផ្អែកលើទឹកភ្លៀង បន្ថែមលើមុខរបរធ្វើស្រែចំការ ក៏មានប្រជាពលរដ្ឋធ្វើនេសាទ ៦.៣១ % និង មុខរបររកអនុផលព្រៃឈើ ៧.១០% ។ ជាមួយគ្នានេះដែរនៅមានអ្នកទិញក្តាម បង្កង ត្រី ពីកន្លែងផ្សេងៗយកមកលក់នៅទីប្រជុំជនតាមបណ្តោយផ្លូវជាតិ ខ្លះទៀតធ្វើជាងជួសជុលម៉ូតូ,រថយន្ត,ទូរស័ព្ទ...... ។ល ។

**<u>តារាងមុខរបរសំខាន់ៗរបស់ប្រជាជនឃុំត្រពាំងរូង</u>**

| ល.រ | ប្រភេទមុខរបបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | មុខរបរកសិកម្ម | | | |
| | ធ្វើស្រែជាចំបង | ៩៩ | ១៩.៥៣ | ស្រែវស្សា |
| | ដាំដំណាំរយៈពេលវែងជាចំបង | ៤៧ | ៩.២៧ | ធូរេន,សាវម៉ាវមង្ឃុត |
| | ដាំដំណាំរយៈពេលខ្លីជាចំបង | ៣១ | ៦.១១ | ពោត ឪឡឹក ដំឡូងមី |
| | ដាំដំណាំបន្លែជាចំបង | ២០ | ៣.៩៤ | ត្រកួន ស្ពៃ ត្រសក់ ននោង ត្រប់ |
| | មុខរបរនេសាទជាចំបង | ៣២ | ៦.៣១ | ត្រី ក្តាម បង្កង (ត្រីទឹកសាប ទឹកប្រៃ |
| | មុខរបរចិញ្ចឹមសត្វជាចំបង | ៧៤ | ១៤.៦០ | គោ,ក្របី,ជ្រូក,មាន់,ទា |

| | | | | |
|---|---|---|---|---|
| | មុខរបរពីអនុផលព្រៃឈើ | ៣៦ | ៧.១០ | ផ្តៅ,សំរ៉ង ផ្សិត |
| ២ | សេវាកម្មជាចំបង | | | |
| | មុខរបរជំនួញជាចំបង | ៧២ | ១៤.២០ | លក់គ្រឿងទេស ផលនេសាទ |
| | ប្រកបមុខរបរជាងជាចំបង | ២ | ០.៣៩ | ជាងម៉ូតូ,ជួសជុលរថយន្ត |
| | មុខរបរដឹកជញ្ជូន | ៥ | ០.៩៩ | តាមរថយន្ត,ទូកយន្ត |
| ៣ | គ្រួសារដែលប្រកបមុខរបរចំរុះក្រៅពីមុខរបរខាងលើ | ៨៩ | ១៧.៥៥ | |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំត្រពាំងរូង ឆ្នាំ ២០០៨

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំត្រពាំងរូងមានកំរិតសិក្សា រហូតដល់ថ្នាក់អនុវិទ្យាល័យ មានសាលាសរុបចំនួន ៣ មានបន្ទប់សិក្សាចំនួន ១១ បន្ទប់ដែលមានសិស្សានុសិស្ស សរុប ៣៧២ នាក់ ( ក្នុងនោះសិស្សស្រី ១៩២ នាក់ ត្រូវជា ៥១.៦១%)។ កុមារគ្រប់អាយុដែលត្រូវចូលរៀនសរុបមាន ៤៧៤ នាក់ អត្រាកុមារគ្រប់អាយុដែលមិនបានចូលរៀនមាន ២១.៥១%។ បើតាមការពិនិត្យជាក់ស្តែងក្នុងឃុំនេះមិនទាន់មានការខ្វះខាតថ្នាក់រៀនទេ តែអត្រាដែលសិស្សមិនបានចូលរៀនខ្ពស់នេះគឺមកពី :

- បញ្ហាខ្វះគ្រូបង្រៀន (បឋមសិក្សា)
- បញ្ហាជីវភាពក្នុងគ្រួសារមានការខ្វះខាត
- ដោយឡែកចំពោះសិស្សដែលបានបញ្ចប់ការសិក្សាពីថ្នាក់អនុវិទ្យាល័យ នៅឃុំត្រពាំងរូងនោះត្រូវជួបបញ្ហាដោយសិស្សត្រូវបន្តទៅរៀននៅវិទ្យាល័យទីរួមខេត្តកោះកុងដែលមានចំងាយផ្លូវ ជាង ៦២ គ.ម ដូច្នេះ ចំពោះសិស្សដែលក្រីក្រត្រូវបោះបង់ចោលការសិក្សានៅក្នុងឆ្នាំ ២០០៨ មានសិស្សត្រូវបន្តទៅរៀននៅខេត្តកោះកុងចំនួន ៩៥ នាក់ ។
- សាលារៀនបឋមសិក្សានៅឃុំត្រពាំងរូងបច្ចុប្បន្នមាន ២ ខ្នង ១ខ្នងធ្វើអំពីឈើប្រក់ហ្វិប្រូ ០១ ខ្នងទៀតធ្វើពីថ្មប្រក់ហ្វិប្រូស៊ីម៉ង់ ឥឡូវសាលារៀនទាំង ០២ ខ្នងនេះមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ។

តារាងស្ថិតិសាលា និង ចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់បឋមសិក្សា | ២ | ៦ | ១៥ | ៣៩៦ | ២៥៣ | ១៣៥ | ១៤,៥៣% |
| ថ្នាក់អនុវិទ្យាល័យ | ១ | ៥ | ៣ | ១៧៨ | ១១៩ | ៥៧ | ៣៣,១៥% |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំត្រពាំងរូង ឆ្នាំ ២០០៨



### ១.១.៦ ស្ថានភាពសុខាភិបាល

#### ១.១.៦.១ ផ្នែកសុខាភិបាល

បច្ចុប្បន្នសេវាសុខភាពនៅឃុំត្រពាំងរូង ពុំទាន់បំពេញបាននូវសេចក្តីត្រូវការរបស់ប្រជាជនទូទាំងឃុំបានឡើយ ព្រោះមានភូមិមួយចំនួន ស្ថិតនៅឆ្ងាយពីមណ្ឌលសុខភាពដូចជាភូមិកោះកុងក្នុង ភូមិព្រែកអង្គុញជាដើម ។ ស្ថិតក្នុងដំណាក់កាលនេះឃុំត្រពាំងរូងក៏ពុំទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិសំរាប់ជួយសំរួលដល់ការទ្រទ្រង់ សុខមាលភាពរបស់ប្រជាពលរដ្ឋបន្ថែមលើមណ្ឌលសុខភាពឡើយ ។

<u>តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ</u>

| ល.រ | មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០១ | ៥ | ០៣ | ១ | ១ |
| ២ | ប៉ុស្តិ៍សុខភាពភូមិ | ០ | ០ | ០ | ០ | ០ |

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ប្រភពនៃការផ្គត់ផ្គង់ទឹកស្អាតពុំទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងឃុំត្រពាំងរូងឡើយ ព្រោះអណ្តូងខ្លះប្រើបានតែរដូវវស្សា ឯទឹកស្រះរីងរាក់នៅរដូវប្រាំង ។

ដូច្នេះអណ្តូងដៃមិនដាក់លូ ឬរៀបឥដ្ឋ និង ស្រះត្រូវជួសជុលស្តាឡើងវិញ ។

<u>តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំត្រពាំងរូង</u>

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | ចំនួនអណ្តូងលូ | ៤២ | ៤១ | ០១ | មិនអាចប្រើបាននៅរដូវប្រាំង |
| ២ | អណ្តូងដៃមិនដាក់លូមិនរៀបឥដ្ឋ | ១៥៥ | ៩៤ | ៦១ | អណ្តូងប្រើបានតែរដូវវស្សា |
| ៣ | ចំនួនស្រះធម្មតា | ០២ | ២ | ០ | រាក់នៅរដូវប្រាំង |

<u>ប្រភព</u>: យកពីស្ថិតិភូមិ



## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

- ឃុំត្រពាំងរូងគឺជាឃុំមួយក្នុងចំណោមឃុំ ៤ របស់ស្រុកកោះកុង ឃុំនេះស្ថិតនៅក្នុងទីរួមស្រុកមាន ប្រជាពលរដ្ឋចំនួន ៥០៧ គ្រួសារ មានមនុស្សសរុបចំនួន ២១៧០ នាក់ ។ ឃុំនេះមានផ្លូវជាតិ លេខ ៤៨ ឆ្លងកាត់ និង មានចំងាយផ្លូវពីឃុំទៅទីរួមខេត្តប្រមាណ ៦២ គ.ម ។ ឃុំត្រពាំងរូងសំបូរទៅដោយព្រៃភ្នំ ដីទំនាបស្ថិតនៅតាម ដងព្រែក ជាទីលំនៅស្ថានរបស់ប្រជាពលរដ្ឋធ្វើចំការដំណាំ និង ស្រែវស្សា ។

- ឃុំត្រពាំងរូងស្ថិតក្នុងរយៈកំពស់ប្រែប្រួលពីរ

  -នៅផ្នែកខាងលិចនៃឃុំត្រពាំងរូងមានកំពស់ ០-៨ម

  -នៅផ្នែកខាងជើង និង ផ្នែកខាងកើតជាតំបន់ភ្នំមានរយៈកំពស់ ២១៦-៤០២ម




### ១.២.២ អាកាសធាតុ

នៅក្នុងឃុំត្រពាំងរូងបញ្ហាអាកាសធាតុក្តៅសើមវាមានការប្រែប្រួលបន្តិចបន្តួចតាមរដូវកាលហើយភ្លៀងធ្លាក់ក្នុងអំឡុងខែឧសភា រហូតដល់ ខែវិច្ឆិកា តែភ្លៀងធ្លាក់ខ្លាំងច្រើននៅក្នុងខែកក្កដា ជាក់ស្តែងដូចជា :

-ក្នុងឆ្នាំ ២០០៣ កំពស់ទឹកភ្លៀងមាន ៨២៩.៨ មម

-ក្នុងឆ្នាំ ២០០៤ កំពស់ទឹកភ្លៀងមាន ៩៥៧.៧ មម

- ក្នុងឆ្នាំ ២០០៥ កំពស់ទឹកភ្លៀងមាន ១.០៤៣ មម

- ក្នុងឆ្នាំ ២០០៦ កំពស់ទឹកភ្លៀងមាន ១,៦៦៦.៥ មម

- ក្នុងឆ្នាំ ២០០៧ កំពស់ទឹកភ្លៀងមាន ៨៨៤.០០ មម

- ក្នុងឆ្នាំ ២០០៨ កំពស់ទឹកភ្លៀងមាន ៩៤១.០០ មម ( ភ្លៀងធ្លាក់ច្រើនក្នុងខែកញ្ញាខុសពីឆ្នាំខាងលើ)

## ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន



ឃុំត្រពាំងរូងមានទីតាំងជាប់ នឹង ផ្លូវជាតិលេខ ៤៨ ដែលមានចំងាយប្រមាណ ៦២ គ.ម ពីទីរួមខេត្តកោះកុង ដោយធ្វើដំណើរតាមផ្លូវជាតិលេខ ៤៨ ឆ្លងកាត់ឃុំតាតៃក្រោម ។ ចំណែកផ្លូវគ្រួសក្រហមមាន ៤ ខ្សែដែលធ្វើរួច មួយខ្សែនៅភូមិត្រពាំងរូងចាប់ពីក្រោមស្ពានតាមបណ្តោយមាត់ព្រែកទៅទិសខាងកើតមានប្រវែង ៨៤0 ម មួយខ្សែទៀតនៅភូមិជីទំនាបគឺចាប់ពីគល់ស្ពានត្រើយខាងជើងតាមមាត់ព្រែកឆ្ពោះទៅចុងភូមិខាងលិចមានប្រវែង ១.១១0 ម និង មួយខ្សែទៀតនៅចំណុចកាឡុងកំពង់ចាមឆ្ពោះទៅភូមិកោះកុងក្នុងប្រវែង ១.១៤៦ ម និង ១ ខ្សែទៀតចាប់ពីផ្លូវជាតិលេខ ៤៨ បែកចូលទៅភូមិព្រែកអង្គញមានប្រវែង ៣.១១៤ ម។

-ចំពោះផ្លូវលំ ឬ ផ្លូវថ្មើរជើងដែលស្ថិតនៅក្នុងឃុំត្រពាំងរូងមានចំនួន 0៩ខ្សែរួមមានប្រវែងសរុប ២៥.៨0៤ ម ចំពោះផ្លូវដីសនេះភាគច្រើនជាផ្លូវចេញពីចុងភូមិទៅភូមិមួយទៀត ពីភូមិទៅចំណុចដែលមានប្រជាពលរដ្ឋ រស់នៅច្រើន (ចំណុចតាភូ វាលស្បូវ )ក្នុងភូមិត្រពាំងរូងភូមិព្រែកអង្គញ និង ភូមិកោះកុងក្នុង ។



## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងឃុំត្រពាំងរូងអាចចែកចេញជា ៧ ចំណាត់ថ្នាក់សាមញ្ញរួមមាន: ដីលំនៅដ្ឋាន ដីកសិកម្ម (ស្រែវស្សា និង ចំការ) ដីព្រៃគំរបព្រៃ(ព្រៃស្រោង) ដីព្រៃកោងកាង (ក្រាស់ ស្តើង )ព្រៃគម្ពោធ និង ដីស្មៅ (ព្រៃពួច, ញិញតាមួង តាមែង ស្មៅកន្ទុយឆ្កែ ស្បូវ ស្មៅថ្នាំងអំពៅ ) ។ ផ្ទៃទឹក និង ខ្សែទឹកសមុទ្រ ស្រះ ដីកសិដ្ឋានចិញ្ចឹមបង្គារ (ដីស្រែចិញ្ចឹមបង្គារចាស់ បច្ចុប្បន្នមិនដំណើរការ ) ។

**<u>តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត</u>**

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ (ហ.ត) | ចំណាត់ថ្នាក់មូលដ្ឋាន |
|---|---|---|---|
| ១ | ដីលំនៅដ្ឋាន-ភូមិ | ១៩៨.៣៤ | ផ្ទះ ឈើហូបផ្លែ |
| ២ | ដីស្រែវស្សា | ១៨៣.៣៤ | ស្រែវស្សា ១រដូវ |
| ៣ | ដីស្រែជាមួយភូមិ | ១៥.៤៥ | ស្រែវស្សា និងផ្ទះ |
| ៤ | ចំការឈើហូបផ្លែ | ៥៣៩.៨៨ | ខ្នុរ សាម៉ាវ មង្ឃុត ធូរេន ដូង ស្វាយ ក្រូច |
| ៥ | ចំការព្រៃដាំ | ២៤៣.៤៥ | អាកាស្យា |
| ៦ | ដីកសិកម្មពនេចរ | ២៧៧.៩៨ | ដាំស្រូវចំការ(ក្លាយជាអចិន្ត្រៃយ៍) |
| ៧ | ចំការចន្ទី | ២៦.២៤ | ចំការស្វាយចន្ទី |

| | | | |
|---|---|---|---|
| ៨ | ចំការឈើហូបផ្លែលើដីភូមិចាស់ | ៤៧.១០ | ខ្នុរ ស្វាយ ដូង ធូរ៉េន |
| ៩ | ល្បាយដីព្រៃលាយដីស្រែ | ៨.៦៦ | ស្រែចាស់លាយដើមស្នាច់មួយៗ |
| ១០ | ល្បាយដីព្រៃលាយដីចំការ | ៩៣៧.៣៨ | ដើមធ្លក តាសេក ចំបក់ ខ្នុរ ស្វាយ ធូរេន |
| ១១ | ព្រៃស្រោង | ៧៤,៧១៣.៩៥ | ក្រញូង គគីរខ្សាច់ ឈើទាល គគីរថ្ម ធ្លក ធ្នង់ ផ្ចឹក ដូងចែម |
| ១២ | ដីគ្មានរុក្ខជាតិដុះគ្របដណ្តប់ | ១.៣៨ | ដីជាំទឹក ថ្ម ខ្សាច់ |
| ១៣ | ព្រៃកាប់ឆ្ការ | ៥៣.១៨ | អំឡុងឆ្នាំ ២០០៧-២០០៨មានការទន្រ្ទានកាប់ព្រៃយកដី |
| ១៤ | ព្រៃចំរុះ( ស្តើង-របោះ ) | ៥៦.២៥ | ស្នាច់ ល្បៀង តាត្រៅ ត្រាច |
| ១៥ | ព្រៃដុះឡើងវិញ | ៥,៤៧៦.៨៧ | កាលពីសម័យអនាធិបតេយ្យការកាប់ឈើធំៗគ្រប់ប្រភេទ ដល់ពេលឥឡូវកន្លែងទាំងនេះដុះព្រៃឡើងវិញ |
| ១៦ | ព្រៃ ឬស្សី | ១៧.៨៣ | សំបូរឬស្សីព្រៃ |
| ១៧ | ព្រៃលិចទឹក | ៧៥៨.៩៨ | សំបូរដើមស្នាច់ក្រញឹប កោងកាង ដើមតាប៊ុន |
| ១៨ | ព្រៃលិចទឹកក្រាស់ | ៨១.៤៦ | សំបូរដើមស្នាច់ កោងកាង ក្រញឹប |
| ១៩ | កោងកាងក្រាស់ | ២៤.៤៣ | សំបូរដើមកោងធំៗ |
| ២០ | កោងកាងស្តើង | ១,២៧០.៦៨ | កោងកាងមួយៗ |
| ២១ | វាលស្មៅ | ២,៧៩៤.២៦ | ស្បូវកន្ទុយឆ្កែ |
| ២២ | ចំការបោះបង់ចោលដុះស្មៅ | ១៥៥.៨៤ | ឆ្នាំ ១៩៨៧-១៩៨៨ កាប់ព្រៃដាំកញ្ឆា ១៩៩១ ដីទាំងនោះដុះស្មៅពេញដូចជា ស្បូវ ស្មៅកន្ទុយឆ្កែ |
| ២៣ | វាលស្មៅលិចទឹក | ៦.១៦ | អញ្ចូត កក់ ស្មៅឆ្អឹងមាន់ |
| ២៤ | ព្រៃគុម្ពោត | ១,១១៤.០២ | សំបូរដើមពួច ញិញ គុយ |
| ២៥ | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | ៤៥២.៧៩ | ដើមធ្លក ចំបក់ តាសេក ដើមពួច ញិញ ព្រូស |
| ២៦ | បឹង | ៩.៦២ | សំបូរត្រី |
| ២៧ | សមុទ្រ | ១,១៦០.៩៧ | ដៃសមុទ្រ |
| ២៨ | ស្រែចិញ្ចឹមបង្គារ | ១០.៦៤ | ឥឡូវបោះបង់ចោល |

បានមកពី GIS

### ១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី

ស្ថានភាពនៃការកាន់កាប់ និង គ្រប់គ្រងដីនៅក្នុងឃុំត្រពាំងរូង សិទ្ធិកាន់កាប់ស្របច្បាប់មានដូចជា

-ក្រុមហ៊ុនព្រៃសម្បទានស៊ីលវើរូដ

-ក្រុមហ៊ុនព្រៃសម្បទានហ្គោត

-ក្រុមហ៊ុនព្រៃសម្បទានធីពាណិជ្ជ

-ឧទ្យានជាតិបូទុមសាគរ

-ក្រុមហ៊ុនហ្គ្រីនរិច

-ភូមិត្រពាំងរូងមានដីលំនៅដ្ឋាន ដីស្រែចំការ ជាដីឯកជន

-ភូមិដីទំនាប មានលំនៅដ្ឋាន ដីស្រែ ចំការ ជាដីឯកជន

ដោយឡែកនៅភូមិព្រែកអង្គុញ ភូមិកោះកុងក្នុង ចំណុចវាលតាភូ វាលស្បូវ ក្នុងភូមិត្រពាំងរូង ស្ថិតក្នុងតំបន់អភិរក្ស ដូច្នេះការកាន់កាប់ដីរបស់ពួកគាត់គឺបានត្រឹមអាស្រ័យផលពុំមានសិទ្ធិចាត់ចែងឡើយ ។ម្យ៉ាងវិញទៀតដីក្នុងឃុំត្រពាំងរូងទូទៅស្ថិតក្នុងតំបន់ការពារ និង ព្រៃការពារ យោងតាមផែនទីផ្នែករដ្ឋបាលព្រៃឈើ ការប្រើប្រាស់ដីក្នុងឃុំដូចបានរៀបរាប់ខាងលើបានដោយសារមានគណៈកម្មការកំណត់ព្រំដីប្រើប្រាស់ក្នុងឃុំត្រពាំងរូង (យោងផែនទីរបស់អង្គការសម្ព័ន្ធមិត្តការពារសត្វព្រៃ (វ៉ាយអេដ) ។

<u>តារាងសង្ខេបស្ថានភាពកាន់កាប់និងគ្រប់គ្រងដី</u>

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហ.ត) | ផ្សេងៗ |
|---|---|---|---|
| ១ | ក្រុមហ៊ុនព្រៃសម្បទានស៊ីលរីវូដ | 102,421.00 | |
| ២ | ក្រុមហ៊ុនព្រៃសម្បទានហ្គេត | 55,500.96 | បញ្ចប់កិច្ចព្រមព្រៀង |
| ៣ | ក្រុមហ៊ុនព្រៃសម្បទានធីពាណិជ្ជ | 71,017.22 | បញ្ចប់កិច្ចព្រមព្រៀង |
| ៤ | ឧទ្យានជាតិបូទុមសាគរ | 1,882.84 | |
| ៥ | ក្រុមហ៊ុនហ្គ្រីនរិច | 1,357.45 | |
| ៦ | ដីផ្សេងៗ | 872.158 | |
| ៧ | ដីសម្បទានសង្គមកិច្ច | 850 | |

**<u>កំណត់សំគាល់</u>** : ចំពោះដីផ្សេងៗសំដៅលើដីដែលមានប្លង់កម្មសិទ្ធិ និងដីមិនទាន់មានប្លង់កម្មសិទ្ធិ ចំពោះដីមានប្លង់កម្មសិទ្ធិសព្វថ្ងៃមួយចំនួនធំស្ថិតនៅក្នុងតំបន់ការពាររបស់អង្គការវ៉ាយអេដ(ក្នុងដែនរដ្ឋបាលព្រៃឈើ និងឧទ្យានជាតិ ) ។ ប្លង់ដីទាំងនោះបានចេញក្នុងអំឡុងឆ្នាំ ១៩៩៦-១៩៩៧ ក្រោយមកក្នុងឆ្នាំ ២០០២ មានការកំណត់ព្រំដីប្រើប្រាស់ ដោយមានការចូលរួមពីឃុំ ស្រុក ខេត្ត និង អង្គការវ៉ាយអេដ ពេលនោះពុំបានសិក្សាឱ្យបានច្បាស់លាស់ បានធ្វើឱ្យដីដែលមានប្លង់កម្មសិទ្ធិមួយចំនួនរបស់ភូមិព្រែកអង្គុញ និង ភូមិកោះកុងក្នុង ស្ថិតនៅតាមផ្លូវជាតិលេខ ៤៨ ក្នុងតំបន់ការពាររហូតមកដល់សព្វថ្ងៃនេះ ។

### ១,៣,៣ ផលិតកម្មកសិកម្ម

ប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូងប្រមាណ ១៩.៥៣% មានមុខរបរធ្វើស្រែវស្សាដោយពឹងផ្អែកលើទឹកភ្លៀងមួយមុខប៉ុណ្ណោះ ។

នៅក្នុងការប្រើប្រាស់ទឹកដើម្បីបំរើអោយវិស័យកសិកម្ម ឃើញថាឃុំត្រពាំងរូងនៅមានការខ្វះខាតនូវប្រពន្ធ័ស្រោចស្រពសំរាប់បង្កបង្កើនផល និង ស្រោចស្រពនូវផលដំណាំ ។ ប្រភពទឹកដែលត្រូវយកមកប្រើគឺ ទឹកអណ្តូង ឬស្រះ

តែប្រភពទឹកទាំងនេះគោកនៅរដូវប្រាំង ។ ដីស្រែឆ្នាំ ២០០៨ មាន ១៨៣.៣៤ ហិកតា ធ្វើបានតែចំនួន ៨៥.៥ ហិកតាប៉ុណ្ណោះ ហើយទិន្នផលទៀតសោត ទទួលបានតែ ១.៣តោន ក្នុង ១ ហិកតា ស្មើនឹង ១១១.១៥ តោន នៅក្នុងឆ្នាំ ២០០៨ ។ នៅឃុំត្រពាំងរូងប្រជាជនមួយចំនួនដាំស្រូវចំការលើផ្ទៃដី ១៦.២០ ហិកតាទទួលបានទិន្នផល ១.0តោន ក្នុង ១ហិកតា ។

តារាងប្រភេទដំណាំកសិកម្ម សំខាន់ៗ និងទិន្នផលទទួលបាន

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី (ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប (ហត) | ដាំបាន (ហត) | ផលសរុប (តោន) | ទិន្នផល (ត/ហត) |
| ១ | ដំណាំស្រូវវស្សា | ១៨៣.៣៤ | ៨៥.៥ | ១១១.១៥ | ១.៣ |
| ២ | ស្រូវចំការ | ១៦.២០ | ១៦.២០ | ១៦.២០ | ១.0 |
| ៣ | ពោត | 0.៥ | 0.៥ | 0.៣ | 0.៦ |
| ៤ | ដំណាំដំឡូងមី | ១.0 | ១.0 | ៣.0 | ៣.0 |
| ៥ | ដំណាំដំឡូងជ្វា | ២.0 | ២.0 | ៣.0 | ១.៥ |

ប្រភព: របាយការណ៏របស់ឃុំត្រពាំងរូង

បច្ចុប្បន្នការងារកសិកម្មដូចដែលបានលើករួចមកហើយនោះ គឺមានការពឹងពាក់លើទឹកភ្លៀងទាំងស្រុង ដែលធ្វើឱ្យការទទួលផលមិនបានទៀងទាត់ ហើយទទួលបានទិន្នផលទាប តែទន្ទឹមនោះឃុំមានផែនការជីកស្រះ និងស្តារស្រះ, បឹង ឡើងវិញ នូវប្រភពទឹកទាំងឡាយដែលមាននៅក្នុងឃុំ ។

តារាងក្រឡាផ្ទៃតាមផលិតភាពដី និង ការប្រើប្រាស់ និងផលិតផល

| **ឃុំត្រពាំងរូង** | | | |
|---|---|---|---|
| **ដីមានផលិតភាពទាប** | | | |
| ១ | ដីចំការបោះបង់ដុះស្មៅ | 143.75 ha | |
| ២ | ព្រៃឫស្សី | 17.83 ha | |
| ៣ | ដីគ្មានរុក្ខជាតិដុះគ្របដណ្តប់ | 1.37 ha | |
| ៤ | ចំការស្វាយចន្ទី | 26.24 ha | |
| ៥ | ដីកប់ខ្មោច | 6 ha | |

| | | | |
|---|---|---|---|
| ៦ | ព្រៃកាប់ឆ្ការ | 53 ha | |
| ៧ | ព្រៃលិចទឹក | 507 ha | |
| ៨ | ព្រៃលិចទឹកក្រាស់ | 70 ha | |
| ៩ | វាលស្មៅលិចទឹក | 6 ha | |
| ១០ | ល្បាយដីព្រៃលាយដីចំការ | 927 ha | |
| ១១ | ល្បាយដីព្រៃលាយដីស្រែ | 8.66 ha | |
| ១២ | ចំការដំណាំលើដីភូមិចាស់ | 47 ha | |
| ១៣ | វាលស្មៅ | 2752 ha | |
| ១៤ | ដីហេដ្ឋារចនាសម្ព័ន្ធ | 10 ha | |
| ១៥ | បឹង | 6 ha | |
| ១៦ | ដីព្រៃកោងកាង | 24 ha | |
| ១៧ | ព្រៃស្រោង | 70412 ha | |
| ១៨ | ចំការឈើហូបផ្លែ | 534 ha | |
| ១៩ | ព្រៃកោងកាងស្តើង | 1270 ha | |
| ២០ | ដីស្រែជាមួយភូមិ | 15 ha | |
| ២១ | សមុទ្រ | 1042 ha | |
| ២២ | ព្រៃដុះឡើងវិញ | 5431 ha | |
| ២៣ | ស្រែបង្កា | 10 ha | |
| ២៤ | ព្រៃគុម្ពោត | 1114 | |

| | | | |
|---|---|---|---|
| ២៥ | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | 442 ha | |
| ២៦ | កសិកម្មពនេចរ | 264 ha | |
| ២៧ | ចំការព្រៃដាំ | 243 ha | |
| ២៨ | ដីលំនៅដ្ឋានភូមិ | 167 ha | |
| ២៩ | ដីស្រែវស្សា | 156 ha | |
| **ដីមានផលិតភាពមធ្យម** | | | |
| ១ | ដីចំការបោះបង់ដុះស្មៅ | 12 ha | |
| ២ | ព្រៃលិចទឹក | 252 ha | |
| ៣ | ព្រៃលិចទឹកក្រាស់ | 11 ha | |
| ៤ | ល្បាយដីព្រៃលាយដីចំការ | 10 ha | |
| ៥ | វាលស្មៅ | 42 ha | |
| ៦ | បឹង | 3 ha | |
| ៧ | ដីព្រៃកោងកាង | 0.38 ha | |
| ៨ | ព្រៃស្រោង | 3273 ha | |
| ៩ | ចំការឈើហូបផ្លែ | 6 ha | |
| ១០ | សមុទ្រ | 78 ha | |
| ១១ | ព្រៃដុះឡើងវិញ | 45 ha | |
| ១២ | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | 10 ha | |
| ១៣ | កសិកម្មពនេចរ | 14 ha | |

| | | | |
|---|---|---|---|
| ១៤ | ដីលំនៅដ្ឋានភូមិ | 31 ha | |
| ១៥ | ដីស្រែវស្សា | 27 ha | |
| **ដីមានផលិតភាពខ្ពស់** | | | |
| ១ | ព្រៃចំរុះ | 56 ha | |
| ២ | ព្រៃស្រោង | 1029 ha | |
| ៣ | សមុទ្រ | 40 ha | |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម




រូបផែនទីផលិតភាពដី

## ១,៣,៤ ធនធានធម្មជាតិ

### ១.៣.៤.១ ធនធានព្រៃឈើ

ដោយឃុំត្រពាំងរូងស្ថិតក្នុងតំបន់ជួរភ្នំក្រវាញផងនោះ ដូចនេះធនធានក្នុងឃុំសំបូរទៅដោយព្រៃឈើធំៗ មានគគីរខ្សាច់ គ្រញូងគគីរថ្ម ផ្ទុង ផ្ចឹក ឈើទាល តាត្រៅ ............។ល។ ព្រៃឈើផ្តល់ផលប្រយោជន៍សំរាប់ធ្វើផ្ទះសំបែងគ្រប់ប្រភេទ មិនតែប៉ុណ្ណោះព្រៃឈើក៏ជាជំរកសត្វព្រៃគ្រប់ប្រភេទរស់នៅ ។ ធនធានព្រៃឈើទាក់ទាញ

យ៉ាងខ្លាំងចំពោះវិស័យអេកូទេសចរធម្មជាតិ ជាពិសេសទៅទៀតក្នុងព្រៃមានសម្បត្តិធម្មជាតិជាច្រើនដូចជា អនុផលព្រៃឈើ វល្លិ៍ផ្តៅ សរ៉ៃង ជ័រសំរ៉ុង..... ។ល។ ម្យ៉ាងទៀតតំបន់ព្រៃភ្នំសំបូរទឹកជ្រោះ ទឹកធ្លាក់និងមានវាលស្មៅតូចធំល្វឹងល្វើយសំរាប់ជាចំណីសត្វទាំងពួងជាអាហារផងដែរ ។



### ១.៣.៤.២ ធនធានជលផល

ឃុំត្រពាំងរូង ជាឃុំមួយជាប់ជាមួយដៃព្រែកតភ្ជាប់ពីសមុទ្រដូចនេះវាមានធនធានជលផលទឹកប្រៃផងដែរ មាន ត្រីស្លុង ក្តាម តែផលទាំងនេះមិនមានលក្ខណៈអាជីវកម្មធំដុំឡើយ ។រីឯផលទឹកសាបសំបូរត្រីគួរសម ដូចជាបង្កង ត្រីរ៉ស់ ត្រីឆ្តោរ ត្រីកាហែរ អន្ទង់....ប្រជាពលរដ្ឋអាចរកប្រាក់កំរៃពីផលនេសាទ បន្ថែមលើមុខរបរធ្វើស្រែចំការដើម្បីសំរាលជីវភាពគ្រួសារមួយកំរិតទៀត ។ នៅអំឡុងខែ មិថុនា កក្កដា រៀងរាល់ឆ្នាំប្រជានេសាទអាចរកបង្កងបានសរុបក្នុង ១ ថ្ងៃទូទាំងឃុំចំនួន ១០០ គ.ក ទៅ ២០០ គ.ក ។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

នៅក្នុងឃុំត្រពាំងរូងការធ្វើស្រែវស្សាពុំសូវបានផលប៉ុន្មានឡើយ ។ តែផលដែលបានមកប្រជាពលរដ្ឋលក់ចេញបានតំលៃជាមធ្យម ១ គ.ក ៩៣៨ រៀល តំលៃខ្ពស់បំផុត ១ គ.ក តំលៃ ១.០៧៥ រៀល និង តំលៃទាប បំផុត ១ គ.ក តំលៃ ៨០០ រៀល ( គិតក្នុងឆ្នាំ ២០០៨ យោងស្ថិតិភូមិ ) ។

រីឯអនុផលព្រៃឈើ : មានច្រើនមុខ តែទីផ្សារមានតែផ្តៅមួយមុខប៉ុណ្ណោះ គឺប្រជាជនរកបានលក់ឱ្យឈ្មួញប្រចាំនៅក្នុងឃុំ ១ ដើមតំលៃ ៥០០ រៀល ក្នុង១ថ្ងៃគាត់អាចរកបាន ២០ ដើម ឬក៏លើសពី ២០ ដើមក៏មាន ។

ផលនេសាទនៅក្នុងឃុំត្រពាំងរូងមាន ២ ប្រភេទគឺ :

-នេសាទទឹកប្រៃដូចជាត្រី

| | | |
|---|---|---|
| +ត្រីស្កុង | ១គ.ក តំលៃ | ១២,០០០ រៀល |
| +ត្រីកំពត | ១ក្បាល តំលៃ | ១០០ រៀល |
| +ក្តាម | ១គ.ក តំលៃ | ១៥,០០០ រៀល |

-ផលនេសាទទឹកសាបដូចជាត្រី

| | | |
|---|---|---|
| +បង្កង | ១ គ.កតំលៃ | ១៣,០០០ រៀល |
| +ត្រីរ៉ស់ | ១ គ.កតំលៃ | ១២,០០០ រៀល |
| +ត្រីឆ្លាំង | ១ គ.កតំលៃ | ៧,០០០ រៀល |
| +អន្ទង់ | ១ គ.កតំលៃ | ១០,០០០ រៀល |
| +ត្រីកាហែល | ១ គ.កតំលៃ | ៥,០០០ រៀល |
| +ត្រីអណ្តែង | ១ គ.កតំលៃ | ១០,០០០ រៀល |

( តំលៃនៅក្នុងឃុំឆ្នាំ ២០០៨ )

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

ប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូងភាគច្រើនទិញអង្ករពីទីរួមខេត្តកោះកុងក្នុងតំលៃ ១ គ.ក ២,៥០០ ៛ ។ ប្រជាពលរដ្ឋនេសាទបានលក់តាមភូមិតំលៃ ១ គ.ក ថ្លៃដូចបានរៀបរាប់ខាងលើស្រាប់ ។ បើសិនឈ្មួញកណ្តាលប្រមូលទិញយកមកលក់នៅតាមផ្លូវជាតិលេខ ៤៨ ឱ្យអ្នកដំណើរឆ្លងកាត់ដូចជា បង្កង ១គ.ក តំលៃ ១៨,០០០ ៛ ក្តាម ១ គ.ក ២០,០០០ ៛ ។

### ១.៤.៣ ឱកាស ឧបសគ្គ

ចំពោះធនធានជលផល គឺជាធនធានដែលមានសក្តានុពលយ៉ាងខ្ពស់ក្រៅពីការផ្តល់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក៏ដូចជាសេដ្ឋកិច្ចជាតិតែការប្រើប្រាស់ធនធានមានការប៉ះពាល់យ៉ាងខ្លាំង គឺធ្វើឱ្យធនធានទទួលរងនូវគ្រោះថ្នាក់យ៉ាងខ្លាំងដូចជា : ការប្រើប្រាស់ថ្នាំបំពុល ការឆក់ ។

# ជំពូក២

# ការវិភាគពីតម្រូវការសំរាប់អនាគត ឧបស័គ្គ និង សក្តានុពល

## ២.១ តំបន់សើប

តំបន់ព្រៃការពារនៅក្នុងឃុំត្រពាំងរូង ស្ថិតនៅក្រោមការការពាររបស់រដ្ឋបាលព្រៃឈើ និង បរិស្ថានដូចនេះមិនអាចធ្វើការពង្រីកផ្ទៃដីធ្វើស្រែចំការ ឬសង់លំនៅដ្ឋានបានឡើយ ព្រោះព្រៃឈើទាំងនេះគឺមានសារៈសំខាន់ណាស់ ។

តំបន់ព្រៃលិចទឹក និង វាលស្មៅតំបន់ជាប់មាត់សមុទ្រ និង ដងព្រែក ជាតំបន់ល្បាប់ដែលសំបូរទៅដោយជីជាតិ តែតំបន់នេះជាតំបន់ដីសើម ជាតំបន់មានជីវចំរុះយ៉ាងពិសេសនិង ជាដែនជំរកត្រីពងកូន ។ តំបន់នេះត្រូវតែរក្សាជាព្រៃលិចទឹកដដែល ហើយមិនអាចមានការពង្រីកដីកសិកម្មនៅក្នុងតំបន់នេះបានទេ ។

## ២.២ ការប្រឈម/ឧបស័គ្គ

ក្នុងឃុំត្រពាំងរូងមានបញ្ហាប្រឈមជាច្រើន តែបញ្ហាប្រឈមដែលមានការពាក់ព័ន្ធដល់ធនធានធម្មជាតិក៏ដូចជាការប្រើប្រាស់ដីមានដូចខាងក្រោម :

-ឃុំត្រពាំងរូងស្ថិតនៅក្នុងតំបន់ឧទ្យានជាតិ និង រដ្ឋបាលព្រៃឈើ ដូច្នេះចំពោះការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋគឺមានការបោះបង្គោលព្រំដីដោយអង្គការវ៉ាយអេដ និង បង្គោលព្រំរបស់ក្រសួងបរិស្ថាន ។

-ដីស្រែចំការបាត់បង់ជីវជាតិ ដែលមានមូលហេតុជាអាទិ៍ ការបាត់បង់ព្រៃឈើ ការធ្វើកសិកម្មមិនមានបច្ចេកទេសគ្រប់គ្រាន់ការដាំដំណាំដដែលៗលើផ្ទៃដីតែមួយការប្រើប្រាស់ជីគីមី មិនត្រឹមត្រូវដែលធ្វើឱ្យដីខ្សោះជីវជាតិ ។

-ទិន្នផលស្រូវចុះទាប ដោយមកពីកត្តាដីមិនមានប្រព័ន្ធស្រោចស្រព ការប្រើប្រាស់ពូជមិនបានត្រឹមត្រូវ ជំងឺនិងសត្វល្អិតបំផ្លាញ ។

-តំរូវការដីបន្ថែមសំរាប់បង្កបង្កើនផល

-ការកាប់រុករានទន្ទ្រានព្រៃលិចទឹក និង ដីផ្សេងៗកាន់កាប់យកធ្វើជាកម្មសិទ្ធិ ។

ការប្រឈមទាំងអស់ខាងលើនេះនឹងនាំមកនូវតំរូវការដីកាន់តែច្រើន ក្នុងនោះមានទាំងដីសំរាប់បង្កបង្កើនផលដីកម្មសិទ្ធិ ហើយជាលទ្ធផលរួមគឺ : ការបាត់បង់ព្រៃលិចទឹក វាលស្មៅ ហើយនាំទៅដល់ការបាត់បង់ធនធានព្រៃឈើជីវចំរុះ ហើយបច្ច័យចុងក្រោយគឺធនធានដីកាន់តែរេចរឹលជាបន្តបន្ទាប់ ។

## ២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្តឃុំត្រពាំងរូង

នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ និង គោលដៅជាយុទ្ធសាស្រ្តឃុំបានធ្វើការលើកឡើងនូវគម្រោងផែនការសំរាប់ពេលអនាគត ដែលក្នុងនោះត្រូវបានកំណត់នូវផែនការជាអាទិភាពដូចខាងក្រោម :

- ការសាងសង់ផ្លូវថ្នល់ ជាបឋមត្រូវបានកំណត់យកការជួសជុលផ្លូវចាស់ និងការកសាងផ្លូវថ្មី ដែលក្នុងនោះរួមមាន : ការក្រាលគ្រួសក្រហមហើយធ្វើការរៀបចំសហគមន៏ថែទាំផ្លូវ ដើម្បីធានាដល់ការប្រើប្រាស់មានភាពយូរអង្វែង ។

- ដើម្បីធានានូវការប្រើប្រាស់ទឹក និង ដើម្បីជំរុញការលើកកំពស់ទិន្នផលស្រូវទៅអនាគត ឃុំមានគោលការណ៏ក្នុងការរៀបចំស្តារស្រះទឹក លើកភ្លឺស្រែ កែប្រែគុណភាពដីស្រែវស្សាដោយប្រើជីធម្មជាតិ ប្រើពូជស្រូវមានគុណភាពខ្ពស់ និង អនុវត្តតាមការណែនាំបច្ចេកទេសពីកសិកម្ម ។

- បច្ចុប្បន្ន នៅក្នុងឃុំត្រពាំងរូងទាំងមូលពុំទាន់ធានាបានក្នុងការប្រើប្រាស់ ទឹកស្អាត និងការថែទាំសុខភាពអនាម័យ នៅឡើយ។ ជាបណ្តើរៗការយល់ដឹងពីប្រជាពលរដ្ឋបាននិងកំពង់ចាប់អារម្មណ៏ទៅលើការសាងសង់អណ្តូងទឹកហើយជាអាទិភាពឃុំក៏មានគម្រោងផែនការក្នុងការសាងសង់ អណ្តូងលូ អណ្តូងស្នប់ និង ធុងចម្រោះ សំរាប់បំរើអោយការប្រើប្រាស់ទឹកស្អាត និងជំរុញការសាងសង់បង្គន់អនាម័យគ្រប់លំនៅដ្ឋាន ជាទូទៅក្នុងមូលដ្ឋានឃុំ ។

- នៅក្នុងការគាំទ្រលើការសិក្សាអប់រំ ឃុំបានកំណត់ចេញជាគោលការណ៏ក្នុងការសាងសង់នូវអគារសិក្សាបន្ថែមនៅក្នុងបរិវេណសាលាបឋមសិក្សាបច្ចុប្បន្នដូចជាបន្ថែមសាលាបឋមសិក្សា និងវិទ្យាល័យ ព្រោះសាលាជាថ្នាលសំរាប់បណ្តុះនូវវិជ្ជាដល់កុមារដែលជាសសរទ្រូងនៃប្រទេសជាតិ ។

- ចំពោះវិស័យសុខភាពសាធារណៈ នៅក្នុងឃុំមានមណ្ឌលសុខភាពមួយ ប៉ុន្តែមិនទាន់អាចបំរើសេវាកម្មជូនប្រជាពលរដ្ឋបានគ្រប់គ្រាន់នៅឡើយទេ ដូច្នេះជាគោលការណ៏ ឃុំបានលើកគម្រោងផែនការ សាងសង់ប៉ុស្តិ៍សុខភាពនៅតាមភូមិដាច់ស្រយាលដូចជាភូមិកោះកុងក្នុងជាដើម។

- នៅក្នុងការថែរក្សា ធនធានធម្មជាតិ ឃុំបានធ្វើការចាប់អារម្មណ៏ទៅលើការស្តារ បឹងធម្មជាតិការដាំដើមឈើឡើងវិញ និង ដាំព្រៃលិចទឹកដូចជា កោងកាង ហើយនឹងការរៀបចំបោះបង្គោលព្រំប្រទល់ដូចជាដែនរដ្ឋបាលព្រៃឈើ ដែនឧទ្យានជាតិបូទុមសាគរ និង ដីព្រៃលិចទឹកឱ្យបានត្រឹមត្រូវ និង ទាន់ពេលវេលាដើម្បីជៀសវាងការលួចជ្រៀតចូលពីជនខិលខូច ។ ការអនុវត្តន៏បាននូវយុទ្ធសាស្ត្រនេះ វាអាចផ្តល់នូវផលប្រយោជន៏យ៉ាងច្រើនដល់ប្រជាជនក្នុងតំបន់ក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការដកយកផលពីធនធាន។



## ២.៤ តម្រូវការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូងបើពិនិត្យទៅតាមបណ្តាឆ្នាំនីមួយៗ ឃើញថា ចំនួនគ្រួសារមានការកើនឡើងក្នុងឆ្នាំ ២០០៥ និង ឆ្នាំ ២០០៦ រីឯឆ្នាំ ២០០៧ មានការថយចុះ លុះដល់ឆ្នាំ ២០០៨ ចំនួនគ្រួសារមានការកើនឡើងរហូតដល់ ៨.៦ ភាគរយឯណោះ តាមសាកសួរព័ត៌មានបានឱ្យដឹងថាកំណើនគ្រួសារនេះ បណ្តាលមកពី :

-នៅក្នុងឃុំត្រពាំងរូងមានក្រុមហ៊ុនចិនមួយមកវិនិយោគដាំដើមកាស្យា ពេលនោះក្រុមហ៊ុនត្រូវការកម្មករច្រើនអ្នកដែលមកធ្វើការនៅទីនោះ គ្រួសារមួយចំនួនបានផ្លាស់ទីលំនៅ នៅក្នុងភូមិឃុំត្រពាំងរូងតែម្តង ។

-ម្យ៉ាងទៀតដោយផលនេសាទមានការថយចុះស្រប និង ច្បាប់ជលផលរឹតបន្តឹងផងនោះ មានគ្រួសារមួយចំនួនបានមកទិញដីភូមិ នៅក្នុងភូមិកោះកុងក្នុង ដើម្បីប្រកបមុខរបរកសិកម្មធ្វើស្រែចំការវិញ ។

បើពិនិត្យទៅលើចំនួនប្រជាជនវិញឃើញថា មានការកើនឡើងគួរឱ្យកត់សំគាល់ក្នុងឆ្នាំ ២០០៥ ប្រជាពលរដ្ឋចំនួន២០៤២នាក់ឆ្នាំ ២០០៦ មាន ១៩៣៩ នាក់ ក្នុងឆ្នាំ ២០០៧ មានចំនួន ២១៩៣ នាក់ ក្នុងឆ្នាំ ២០០៨ មានចំនួន ២១៧០ នាក់ ។ បើសិនជាពិនិត្យមើលទៅលើកុមារក៏មានការកើនឡើង ដែលអាចធ្វើឱ្យមានការកើនឡើងនូវកង្វះខាតនូវទីកន្លែងសិក្សា ។ ហើយក្នុងនោះដែរចំពោះដីធ្លីនៅក្នុងឃុំក៏មានការខ្វះខាតដីក្នុងការពង្រីកលើវិស័យ

កសិកម្មដែរ ដូច្នេះពីមួយឆ្នាំទៅមួយឆ្នាំប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់ ជាកត្តាមួយធ្វើឱ្យយើងត្រូវការកត់សំគាល់ទៅលើ សក្តានុពលមួយចំនួនដូចជា លទ្ធភាពនៃការពង្រីកអគារសិក្សា ការបង្កើនមុខរបរ ការធ្វើស្រែតាមបែបបច្ចេកទេសការបង្កើននូវទិន្នផលកសិកម្មការរៀបចំប្រព័ន្ធស្រោចស្រពការអភិរក្សនូវធនធានធម្មជាតិ និង កំណត់នៃការប្រើប្រាស់ ធនធានឱ្យបានសមស្របទើបធានាបាននូវអត្រាកំណើន ។

| ចំនួនគ្រួសារ/ប្រជាជន | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើន/ឆ្នាំ |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | **៤២៧** | **៤៥២** | **៤៦៧** | **៥០៧** | **-** | - |
| អត្រាកំណើនគ្រួសារ | - | ៥.៩% | ៣.៣% | ៨ | **៥.៩%** | ៣០ គ្រួសារ |
| ចំនួនប្រជាជនសរុប | **២០៤២** | **១៩៣៩** | **២១៩៣** | **២១៧០** | **-** | - |
| អត្រាកំណើនប្រជាជន | - | -៥.០% | ១៣.១% | -១.០% | **២.៣%** | ៥០ នាក់ |

ផ្អែកតាមការគណនាអត្រាកំណើនចំនួនគ្រួសារពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៨ ឃើញថាអត្រាកំណើនមាន ៥.៩% ស្មើនឹង ៣០ គ្រួសារក្នុង ១ ឆ្នាំ ។

ផ្អែកតាមទិន្នន័យព័ត៌មាននៃផែនការអភិវឌ្ឍន៍ឃុំ និង តាមរយៈការគណនារកអត្រាកំណើនរបស់ប្រជាពលរដ្ឋឃើញថាចំនួនប្រជាជនពីមួយឆ្នាំទៅមួយឆ្នាំ មានការប្រែប្រួលកើនឡើង ឆ្នាំខ្លះមានការថយចុះកត្តានេះគឺអាស្រ័យដោយមានការយល់ដឹងពីកម្មវិធីពន្យាកំណើត ពិសេសគឺការចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ហើយនិងមួយចំនួនទៀតទៅធ្វើកម្មករសំណង់នៅភ្នំពេញ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏អត្រាកំណើនជាមធ្យម ២.៣ % ដែលក្នុងនោះមានការកើនឡើងក្នុងមួយឆ្នាំ ៥០ នាក់ ។

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

<u>តារាងការធ្វើចំណោលប្រជាសាស្ត្រ</u>

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម០៥ឆ្នាំ | ២៥៦ | ១៣០ | ២៨៣ | ១៤៤ | ៣០៩ | ១៥៧ |
| អាយុ ០៥ឆ្នាំ | ៧៩ | ៣៦ | ៨៧ | ៤០ | ៩៥ | ៤៤ |
| អាយុពី ៦-១១ឆ្នាំ | ៣២៣ | ១៧០ | ៣៥៧ | ១៨៨ | ៣៩១ | ២០៦ |
| អាយុពី ១២-១៤ឆ្នាំ | ១៩៤ | ៩៤ | ២១៥ | ១០៤ | ២៣៥ | ១១៤ |
| អាយុពី ១៥-១៧ឆ្នាំ | ១៩៣ | ៩០ | ២១៤ | ៩៩ | ២៣៤ | ១០៨ |

| | | | | | | |
|---|---|---|---|---|---|---|
| អាយុពី ១៨-២៤ឆ្នាំ | ៣១០ | ១៤៩ | ៣៤៣ | ១៦៤ | ៣៧៦ | ១៨០ |
| អាយុពី ២៥-៦០ឆ្នាំ | ៩២៤ | ៤៤៨ | ១០២១ | ៤៩៥ | ១១១៩ | ៥៤២ |
| អាយុពី៦១ឆ្នាំឡើងទៅ | ៩១ | ៤៤ | ១០០ | ៤៨ | ១១០ | ៥៣ |
| **ចំនួនប្រជាជនសរុប** | ២៣៧០ | ១១៦០ | ២៦២០ | ១២៨២ | ២៨៧០ | ១៤០៥ |
| **ចំនួនគ្រួសារសរុប** | **៥៥៤** | | **៦១២** | | **៦៧១** | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំង បើពិនិត្យទៅលើកំណើនក្នុងរយៈពេល៥ ឆ្នាំម្តងសំរាប់រយៈពេល ១៥ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យម ២.៣% ក្នុងនោះ ស្មើនឹង ៥០ នាក់ ក្នុង មួយឆ្នាំហើយនិង ៥.៩% ស្មើនឹង ៣០ គ្រួសារ ក្នុងមួយឆ្នាំនោះបើពិនិត្យទៅលើបរិមាណផ្ទៃដី ដែលអាចប្រើប្រាស់ បាននៅមានកំរិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៍ដល់ការអភិវឌ្ឍន៍ដែរ ។ ព្រោះអត្រាកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូងគឺ វាពាក់ពន្ធ័ទៅលើការអភិវឌ្ឍន៍ធនធានដែលមានក្នុងឃុំ ពិសេសបរិមាណដីដែលអាចបង្កើនន្ធូវបរិមាណផល ដើម្បីធានាស្បៀងក្នុងតំបន់ ។

## ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋាននៅឃុំត្រពាំងរូងគឺ សំដៅទៅដល់ដីដែលប្រើប្រាស់សំរាប់សង់ផ្ទះ និង សំរាប់ដាំដំណាំសួនគ្រួសារ ។ សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ១៩៨.៣៤ ហិកតា សំរាប់ប្រជាជនប្រមាណ ៣៥៣ គ្រួសារ គិតជាមធ្យមមាន ០.៥៦ ហិកតា ក្នុងមួយគ្រួសារនេះជាទំហំធំដូចនេះយើងមិនអាចយកតួលេខនេះទៅគណនារកតម្រូវការដីលំនៅដ្ឋានសំរាប់កំណើនគ្រួសារឆ្នាំ២០២២ បានឡើយ ។ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមតាមគោលការណ៍ដីសម្បទានសង្គមកិច្ចមួយគ្រួសារត្រូវបាន ០.៣៦ ហិកតា (យោងអនុក្រិត្យលេខ:១៩ អ ន ក្រ .បក ចុះថ្ងៃទី១៩ខែមិនា ឆ្នាំ ២០០៣)ដែលទំហំនេះអាចជាទំហំសមស្របសំរាប់ការតាំងលំនៅដ្ឋាន និង សួនដំណាំ ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន ១៥៤ គ្រួ.x ០.៣៦ = ៥៥.៤៤ ហាត.
- កំណើនគ្រួសារ ២០២២ ១៦៤ គ្រួ. x ០.៣៦ = ៥៩.០៤ ហាត.

សរុប **១១៤.៤៨ ហាត.**

## ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្មគឺរួមមានដីសំរាប់ស្រែវស្សា និងចំការដំណាំសំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៧៣៨.៦៧ ហិកតា សំរាប់ប្រជាជនសរុប ៥០៧ គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់ មួយគ្រួសារមាន ១.៤ ហិកតា។

តែប្រជាជននៅក្នុងឃុំត្រពាំងរូងនៅមានមុខរបរសំខាន់មួយទៀតគឺរបបរនេសាទនៅតាមដងព្រែកត្រពាំងរូង និង នៅតាមបឹងបួរ ដែលតាមស្ថិតិគឺមាន ៦.៣ % ប៉ុណ្ណោះគ្រួសារដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្ម គឺមានប្រមាណ ១៩៧ គ្រួសារ ស្មើនឹង ៣៨.៨ % ដែលអាចមានដីជាមធ្យមទំហំ ៣.៧៤ ហិកតា ដែលជាទំហំសមស្រប សំរាប់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាលបែបនេះ ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | | | |
|---|---|---|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីកសិកម្ម | ៣១ គ្រួ. | x ៣.៧៤ | = | ១១១.២៣ ហត. |
| - ចំនួនគ្រួសារមានដីតិចជាង ១ហិកតា | ៤២ គ្រួ. | x ៣ | = | ១២៦ ហត. |
| - កំណើនគ្រួសារ ២០២២ | ១៦៤ គ្រួ. | x ៣.៧៤ | = | ៦១៤.៩៣ ហត. |
| | សរុប | | | **៨៥៧.១៧ ហត.** |

បើតាមឆ្នាំគោល ២០០៨ មាន ៥០៧ គ្រួសារ មានអ្នកធ្វើស្រែ និង ចំការ មានចំនួនតែ ១៩៧ គ្រួសារ ដូច្នេះរហូតដល់ឆ្នាំ ២០២២ កំណើនគ្រួសារមានចំនួន ១៦៤ គ្រួសារ អាចមានគ្រួសារដែលត្រូវធ្វើស្រែចំការចំនួន ៦៤គ្រួសារតែប៉ុណ្ណោះ ដូច្នេះសរុបគ្រួសារដែលបច្ចុប្បន្នពុំទាន់មានដីស្រែចំការ និងកំណើនគ្រួសារដែលត្រូធ្វើស្រែនៅឆ្នាំ ២០២២ មានចំនួន **១៣៧** គ្រួសារ ។

ដូច្នេះតម្រូវការដីកសិកម្មសំរាប់ឆ្នាំ ២០២២ ស្មើ **៥១២.៨** ហិកតា ខាងលើនេះជាការវិភាគទៅតាមទំហំដី តែបើយើងវិភាគទៅតាមចំនួនប្រជាជន ផ្ទៃដីដំណាំស្រូវគឺយើង ឃើញថាទិន្នផលស្រូវមាន ១.៣ តោន ក្នុងមួយហិកតា ហើយប្រជាជនម្នាក់ៗត្រូវការតែ ២៣០ គក្រ. ក្នុងមួយឆ្នាំ តាមស្ថិតិឃុំផ្ទៃដីស្រែមានប្រមាណ ១៨៣.៣៤ ហិកតា ទទួលបានផលស្រូវ ២៣៨.៣៤តោន តម្រូវការជាក់ស្តែង ៤៩៩.១០០ តោន នៅខ្វះតម្រូវការ ២៦០.៧៦ តោនស្មើនឹង ៥៨ % ទៀតទើបគ្រប់តំរូវការ ។ បើសិនយើងកែប្រែនូវគុណភាពដី អោយវាប្រសើរជាងមុន នោះយើងអាចបានទិន្នផលស្រូវលើសជាងមុន ដូចជា ០១ ហិកតា បាន ១.៨ តោន ដូចនេះបើគិតទៅផ្ទៃដីស្រែមាន ១៨៣.៣៤ ហិកតា ទទួលបានផលសរុបប្រចាំឆ្នាំបាន ៣៣០.០១២ តោន តែប្រជាពលរដ្ឋ តំរូវការជាក់ស្តែង ៤៩៩.១០០ តោន ដូចនេះនៅខ្វះតំរូវការ ១៦៩.០៨៨ តោន ស្មើនឹង ៣៣.៨៦ % នៃតំរូវការសរុប ។ ដូចនេះតំរូវការដីស្រែបន្ថែមក្នុងពេលបច្ចុប្បន្ន ៩៣.៩៤ ហិកតា :

-នៅឆ្នាំ ២០២២ មានប្រជាជនសរុប ២,៨៧០ នាក់ កើនលើសឆ្នាំ ២០០៨ ចំនួន ៧០០ នាក់ ដូច្នេះតំរូវការស្រូវបន្ថែម សំរាប់ ៧០០ នាក់ ស្មើនឹង ១៦១ តោន ស្មើនឹងផ្ទៃដីស្រែសរុប ៨៩.៤៤ ហិកតា ។ ដូច្នេះផ្ទៃដីស្រែសរុបពីពេលបច្ចុប្បន្នរហូតដល់ឆ្នាំ ២០២២ ស្មើនឹង **១៨៣.៣៨** ហិកតា ។

-នៅឃុំ ត្រពាំងរូង មានគំរោងដីសម្បទានសង្គមកិច្ច ដែលស្ថិតនៅភូមិ កោះកុងក្នុង (ចំណុចកាឡុងកំពុងចាម) មានទំហំប្រមាណ ៨៥០ ហិកតា សំរាប់បំរើអោយតំរូវការរបស់ស្រុកក៏ដូចជាឃុំក្នុងការបែងចែកដីដល់ប្រជាជនក្រីក្រគ្មានផ្ទះសំបែងនិងគ្រួសារយោធិនដែលចូលនិវត្តន៍ ពលី ពិការ... ។ល។ សំរាប់ការសាងសង់

លំនៅដ្ឋាន និង ដីសំរាប់ប្រកបរបរធ្វើស្រែចំការ ។

-យោងតាមកំណើនប្រជាពលរដ្ឋពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០២២ ដែលត្រូវការដីស្រែ និងដីចំការ និងប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្នដែលពុំមានដីធ្វើស្រែចំការឃុំត្រពាំងរូង បានគ្រោងសុំពង្រីកដីកសិកម្មទំហំ ៥១២.៨៣ ហិកតា ក្នុងនោះដីស្រែមានទំហំ១៨៣.៣៨ ហិកតា ដីសំរាប់ធ្វើចំការមានទំហំ៣២៩.៤៥ហិកតា ។

### ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយនៅឃុំត្រពាំងរូងនៅមានព្រៃឈើធំៗ ព្រៃលិចទឹក និងវាលស្មៅសំបូរបែបនៅឡើយ ដូច្នេះដីដែលបានកំណត់នៅក្នុងតំបន់រសើប និង ដីផ្សេងៗទៀតដែលមិនបានកំណត់ទៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវតែទុកឱ្យនៅជាដីព្រៃ និង វាលស្មៅ សំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ ពិសេសគឺបណ្តាបឹងបួរធម្មជាតិដែលជាប្រភពដ៏ចំបងសំរាប់ធនធានជលផល ។

### ២.៤.៥ តម្រូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬ ដីទីប្រជុំជនដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច វត្ត អាស្រម សាលាឆទាន ក៏គិតគូរក្នុងនេះដែរ) តែក្នុងនោះក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធសង្គម ត្រូវបានកំណត់ជារួម ១១៤.៤៨ ហិកតាជាមួយនឹងដីត្រៀមបំរុងសំរាប់ពង្រីកទីប្រជុំជន។

តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ០០ | ០០ | ០០ |
| សាលាបឋមសិក្សា | ០២ | ០៣ | ០១ |
| សាលាអនុវិទ្យាល័យ | ០១ | ០១ | ០០ |
| សាលាវិទ្យាល័យ | ០០ | ០១ | ០១ |
| មណ្ឌលសុខភាព | ០១ | ០១ | ០០ |
| ប៉ុស្តិ៍សុខភាព | ០០ | ០១ | ០១ |
| ស្រះទឹកស្អាត | ០២ | ០២ | ០ |
| អណ្តូងទឹកស្អាត | ៤១ | ៤១ | ០ |
| កន្លែងចាក់សំរាម | ០ | ១ | ១ |
| ទីតាំងផ្សារ | ០ | ០ | ០ |
| ប៉ុស្តិ៍នគរបាល | ០១ | ០១ | ០ |

**កំណត់សំគាល់ :** ប៉ុស្តិ៍នគរបាលពុំទាន់មានទីតាំងពិតប្រាកដ

## ២.៤.៥.១ តម្រូវការសាលារៀន

ផ្ទៃដីសំរាប់កសាងសាលារៀននៅក្នុងឃុំគឺមិនមានបញ្ហាចោទអ្វីឡើយព្រោះ :

-ដីសាលាបឋមសិក្សារុងផ្លាមកេសន ១ សាលា និង អនុវិទ្យាល័យ ១ សាលាដែលស្ថិតនៅលើដីមានផ្ទៃក្រឡា ១.៤៦ ហិកតា នេះបញ្ជាក់ឱ្យឃើញថា ឃុំអាចអភិវឌ្ឍន៍នូវសាលាបតេយ្យ បឋមសិក្សា និង អនុវិទ្យាល័យ បន្ថែមសំរាប់ពេលអនាគតបាន ។

-ដីសាលាបឋមសិក្សាវត្តត្រពាំងរូងមាន ០១ សាលានៅលើផ្ទៃដី ១.០០ ហិកតា នេះបញ្ជាក់ឱ្យឃើញថាដីសំរាប់កសាងសាលាមតេយ្យ ឬ សាលាបឋមសិក្សាបន្ថែមបានយ៉ាងស្រួល ។

ឃុំត្រពាំងរូងនៅពុំទាន់បានបំពេញនូវតំរូវការសិក្សារបស់សិស្សនៅឡើយជាអាទិ៍ដូចជា នៅគំរោងផែនការ ១៥ ឆ្នាំ ខាងមុខតំរូវការលើអគារសិក្សាផ្អែកតាមបរិមាណសិស្សានុសិស្សគឺ សាលាបឋមសិក្សា អនុវិទ្យាល័យក៏ដូចវិទ្យាល័យ បើពិនិត្យទៅតាមការគណនាកំណើនប្រជាពលរដ្ឋឃើញថាតំរូវការទាំងនេះអាចផ្តល់ឱកាសឱ្យឃុំអាចអភិវឌ្ឍទៅ តាមលទ្ធភាពជាបណ្តើរៗ ដែលក្នុងនោះសិស្សមត្តេយ្យមានចំនួនតិចនោះអាចខ្ចីបន្ទប់នៃសាលាបឋមសិក្សារៀនបាន ឯសាលាបឋមសិក្សាឃុំមានគំរោងពង្រីក ០១ អគារស្មើ ០៥ បន្ទប់។ សាលាអនុវិទ្យាល័យពុំទាន់តំរូវការនៅឡើយដល់ឆ្នាំ ២០២២ តែតំរូវការសាលាវិទ្យាល័យ ០១ អគារមាន ៥ បន្ទប់បន្ថែមនៅពេលអនាគត ឆ្នាំ ២០២២ ។

**តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២**

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយសិក្សា | ៧៩ | ០ | ១ | ៨៧ | ០ | ០ | ៩៥ | ០ | ១ |
| ថ្នាក់បឋមសិក្សា | ៣២៣ | -១ | -៣ | ៣៥៧ | ០ | ១ | ៣៩១ | ១ | ៣ |
| ថ្នាក់អនុវិទ្យាល័យ | ១៩៤ | -១ | -៣ | ២១៥ | ០ | -១ | ២៣៥ | ០ | ១ |
| ថ្នាក់វិទ្យាល័យ | ១៩៣ | ០ | ២ | ២១៤ | ១ | ៤ | ២៣៤ | ០ | -២ |

កត្តាសន្មត់ : សាលា ០១ ខ្នង មានចំនួន ០៥ បន្ទប់ សិស្សក្នុង ០១ ថ្នាក់ មានចំនួន ៥០ នាក់ ហើយក្នុង ០១ ថ្ងៃ រៀនចំនួន ០២ វេណ។

## ២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

### ក. សេវាកម្មសុខភាព

ស្ថិតក្នុងដំណាក់កាលនេះ ឃុំត្រពាំងរូងក៏ពុំទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិសំរាប់ជួយសំរួលដល់ការទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋបន្ថែមលើមណ្ឌលសុខភាពឡើយ ។

- ចំងាយមធ្យមពីភូមិទៅមណ្ឌលសុខភាពឃុំ ចំពោះភូមិកោះកុងក្នុង មានចំងាយ ២០ គីឡូម៉ែត្រ ។
- ផ្អែកទៅតាមស្ថានភាពភូមិសាស្រ្ត នៃឃុំត្រពាំងរូងដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា និង មានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំ បណ្តាលអោយមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រាប់គ្រាន់នៅឡើយ ។
- ចំពោះការការពារសុខមាលភាពប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងរូង នៅចោទជាបញ្ហាហើយនៅរយៈពេល ១៥ ឆ្នាំខាងមុខ ឃុំមានផែនការបង្កើតប៉ុស្តិ៍សុខភាពមួយនៅភូមិកោះកុងក្នុង ។




## ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំត្រពាំងរូង បច្ចុប្បន្ននៅតែជាបញ្ហាចំបងនៅឡើយព្រោះថា ចំពោះអណ្តូងទឹក និង ស្រះទឹក នៅក្នុងឃុំដែលបានសាងសង់ពីមុននោះមួយចំនួនត្រូវបានខូចខាត ដូច្នេះជាជំហានដំបូងនៃការអភិវឌ្ឍន៍ត្រូវស្តារ និង ជួសជុលនូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅពេលអនាគត ឃុំត្រូវបន្ថែមនូវគម្រោងផែនការក្នុងការជីកស្រះស្តុកទឹកស្អាត និងអណ្តូងទឹកស្អាត ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និង សាសនា

នៅក្នុងការអភិវឌ្ឍន៍ ទៅលើផ្នែកវប្បធម៌ជាកត្តាមួយចូលរួមចំណែកជំរុញអោយមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា ។ រាល់ទីតាំងនីមួយៗតាមបណ្តាភូមិ ត្រូវបានផ្តល់លទ្ធភាព និង ជួយសំរួលដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់មានឱកាសចូលរួមពង្រីក លើការផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលជាសរសរទ្រូងនៃប្រទេសជាតិអោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់ ។

<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | ០២ | ០៥ | ៣ |
| វត្តអារាម | ០២ | ០២ | ០ |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមានក្នុងឃុំត្រពាំងរូងឃើញថា ផ្លូវគ្រួសក្រហមមួយចំនួនដែលបានសាងសង់ពីមុន បច្ចុប្បន្នត្រូវបានត្រូវបានខូចជាអន្លើៗ នៅរយៈពេលខាងមុខឃុំមានគំរោងធ្វើការជួសជុលផងដែរ ។

នៅរយៈពេល១៥ឆ្នាំខាងមុខឃុំ និង លើកគម្រោងសាងសង់ផ្លូវគ្រួសក្រហមបន្ថែមលើផ្លូវលំថ្មើរជើងដែលស្ថិតនៅតាម មាត់ព្រៃកត្រពាំងរូងខ្លះបែកចេញពីផ្លូវជាតិលេខ ៤៨ ចូលភូមិ ទីប្រជុំជនសរុបមាន ០៩ ខ្សែនិងមានប្រវែង ២៥,៨០៤ ម ។

នៅយេៈពេល១៥ឆ្នាំខាងមុខឃុំ នឹង លើកគម្រោងសាងសង់ផ្លូវគ្រួសក្រហម បន្ថែមលើផ្លូវលំថ្មើរជើងដែលស្ថិតនៅតាមមាត់ព្រៃកត្រពាំងរូងខ្លះបែកចេញពីផ្លូវជាតិលេខ ៤៨ ចូលភូមិខ្លះបែកចេញពីផ្លូវជាតិលេខ ៤៨ ឆ្ពោះទៅកន្លែងទេសចរណ៍ដូចជា ទឹកធ្លាក់ដ៏ល្អប្រណិតជាច្រើនកន្លែងសរុបទាំងអស់ក្នុងឃុំមាន ៥៦ ចំណុច ជាពិសេសទឹកធ្លាក់នៅចំណុចវាលឆ្កែស្លាប ភ្នំទីក្រុងមេឃ ទីប្រជុំជន សរុបមាន ០៩ ខ្សែ និង មានប្រវែង ២៥,៨០៤ម ។ ប៉ុន្តែការគ្រោងធ្វើផ្លូវលំគ្រួសក្រហមជួបការលំបាក ព្រោះផ្លូវលំទាំងនេះត្រូវឆ្លងកាត់ តំបន់ការពារក៏ដូចជាតំបន់រដ្ឋបាលព្រៃឈើផងដែរ គឺមានការហាមឃាត់ពីអង្គការការពារសត្វព្រៃ និង រដ្ឋបាលព្រៃឈើ ។ តែផ្លូវលំនៅក្នុងភូមិឃុំវិញមិនប៉ះពាល់ដល់តំបន់ការពាររបស់អង្គការវ៉ាយអេដ និង រដ្ឋបាលព្រៃឈើទេ តែវាមានបញ្ហាត្រង់យកគ្រួសក្រហមដែលស្ថិតនៅក្នុងតំបន់ការពារមកចាក់ធ្វើផ្លូវមិនបានដោយមានការហាមឃាត់ពីស្ថាប័នខាងលើផងដែរ ។ ដូច្នេះរាល់គម្រោងស្ថាបនាក្នុងឃុំ ស្ថាប័នពាក់ពន្ធ័ខាងលើគួរផ្តល់ការអនុញ្ញាត និង ត្រួតពិនិត្យអោយបានច្បាស់លាស់បើពុំនោះទេរាល់គម្រោងស្ថាបនាដែលឃុំយល់ថាបំរើផលប្រយោជន៍ប្រជាពលរដ្ឋ និង កាត់បន្ថយភាពក្រីក្រត្រូវរាំងស្ទះព្រោះផ្លូវទាំងនេះជាសេវាមួយដ៏ល្អសំរាប់ដឹកផលិតផលផ្សេងៗ យកទៅលក់នៅទីផ្សេងៗ ជាពិសេសនោះ កន្លែង

ទេសចរណ៏ ដែលបានរៀបរាប់ខាងលើ ។

ក្នុងឃុំត្រពាំងរូងបច្ចុប្បន្នស្ពានឈើនៅតាមផ្លូវគ្រួសក្រហមចូលទៅភូមិព្រែកអង្គុញមានការខូចខាតយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យប្រជាពលរដ្ឋដឹកទំនិញឆ្លងកាត់ពិបាក ដូច្នេះតំរូវការក្នុងពេលអនាគតតំរូវឱ្យមានការសាងសង់លូជ្រុងមានប្រវែង ៧ គុណ ៥ ម៉ែត្រ ។

<u>តារាងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត</u>

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ៥0 | ៥0 | 0 |
| ផ្លូវក្រាលគ្រួសក្រហម | ៦.២0៥ | ៣៤.00 | ២៥.៨0៤ |
| ប្រវែងផ្លូវលំធ្វើរជើង | ២៥.៨0៤ | 0 | 0 |
| ចំនួនស្ពានថ្ម | ៨ កន្លែង | ៨ កន្លែង | 0 |
| ចំនួនស្ពានឈើ | 0១ កន្លែង | 0១ កន្លែង | 0 |
| ចំនួនលូឆ្លងកាត់ | 0១ កន្លែង | 0១ កន្លែង | 0 |

# ជំពូក ៣

# ផែនការប្រើប្រាស់ដីអនាគត

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំត្រពាំងរូង ធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ និង អភិរក្ស អភិវឌ្ឍ ទៅលើធនធានទាំងនោះ អោយមាននិរន្តរភាព ដែលក្នុងនោះរួមមានដូចជា : ស្ថានភាពដី នៃ ព្រៃភ្នំ ព្រៃលិចទឹក គឺជាបរិស្ថានធម្មជាតិមួយ ដ៏ល្អប្រសើរសំរាប់មជ្ឈដ្ឋានរស់នៅ នៃធនធានជលផលក្នុងតំបន់នោះ ។ នៅក្នុងក្របខណ្ឌនៃការរស់នៅរបស់ពពួកសត្វព្រៃភាវរស់គឺជាបណ្តាញនៃប្រពន្ធ័អេកូឡូស៊ីនៅក្នុងមជ្ឈដ្ឋាន នាទីព្រៃលិចទឹកដែលបានផ្តល់នូវសារៈប្រយោជន៏អោយគ្នាទៅវិញទៅមក ជាអាទិ៏ដូចជា ព្រៃលិចទឹកផ្តល់នូវទីជំរកដល់ពពួកភាវរស់ និងសត្វផ្សេងៗដែលរស់នៅក្នុងព្រៃលិចទឹកដូចជា %

-ព្រៃភ្នំ ផ្តល់នូវទីជំរកដល់ពពួកសត្វទាំងឡាយដូចជា សត្វដំរី ខ្លាធំ ខ្លាឃ្មុំ ឈ្លូស ប្រើស ជ្រូកព្រៃនិងសត្វផ្សេងៗជាច្រើនប្រភេទ ។

-ព្រៃលិចទឹកផ្តល់នូវទីជំរកដល់ពួកភាវរស់ និង សត្វផ្សេងៗដែលរស់នៅក្នុងព្រៃលិចទឹក ដូចជា ក្តាមថ្ម បង្កាកន្ទាយ អណ្តើក ពស់ ស្វា អន្សង ត្រកួត និង សត្វស្លាបជាច្រើនប្រភេទទៀត ។

ទាំងនេះគឺជាសក្តានុពលមួយដែល ផ្តល់នូវសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានសំរាប់ការដកយកអនុផលពីព្រៃលិចទឹកដូចជា វល្លិ៍ ផ្តៅ ផ្សិត ជ័រវ៉ុងផ្លែសំរ៉ង់ និង ដើមរុក្ខជាតិខ្លះយកមកធ្វើឱសថសំរាប់ព្យាបាល ។ ឯព្រៃលិចទឹកមានអនុផលដូចជា ខ្យងត្រដិត ចាក់ច្រែង និង ព្រៀង ។ រួមមកព្រៃភ្នំ ព្រៃលិចទឹកវាមានសារៈប្រយោជន៍សំរាប់ជារបាំងការពារខ្យល់ និង លំនឹងបរិស្ថាន ។

## ៣.១.២ តម្រូវការដីតាមប្រភេទ

អត្រាកំណើនប្រជាពលរដ្ឋគឺជាការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ ទៅលើធនធានដូច្នេះយើងត្រូវតែធ្វើការពិចារណាធនធានដែលមាននៅក្នុងឃុំ ។ ផ្អែកទៅតាមអត្រាកំណើនខាងលើ ឃុំបានរៀបចំនូវគម្រោងផែនការទៅលើតម្រូវការពង្រីកដីភូមិដោយបានកំណត់ទៅលើផ្ទៃដីស្ថិតនៅ ០២ ចំណុចផ្សេងគ្នា :

-ចំណុចវាលស្បូវជាដីចំការបោះបង់ចោលដុះស្មៅ និង មានប្រជាពលរដ្ឋរស់នៅ ដីសំរាប់ពង្រីកភូមិមានទំហំប្រមាណ ៤០ ហិកតា ដែលមានលេខកូដ F1200-01 ផ្នែកខាងក្រោយដីលំនៅដ្ឋានជាដីស្រែបច្ចុប្បន្នប្រជាពលរដ្ឋពុំហ៊ានធ្វើនៅទីនោះឡើយ ព្រោះជាតំបន់ការពារ ។ ដូច្នេះនៅចំណុចនេះបើពង្រីកសំរាប់ដីភូមិមិនមានផលប៉ះពាល់ដល់ធនធានធម្មជាតិឡើយ ។

-ចំណុចព្រែកបើស ជាដីភូមិចាស់ចំការបោះបង់ចោល និង មានប្រជាពលរដ្ឋរស់នៅមួយចំនួន នៅចំណុចនេះក្នុងរយៈពេល ១៥ ឆ្នាំ ឃុំមានគំរោងពង្រីកដីភូមិ ដែលមានទំហំប្រមាណ ៧៦ ហិកតា ដែលមានលេខកូដ F1200-02 ដីនេះសព្វថ្ងៃស្ថិតនៅក្នុងតំបន់ការពារ ការពង្រីកភូមិនៅលើទីតាំងនេះមានផលប៉ះពាល់តិចតួចដល់ធនធានធម្មជាតិ តែវាមានលក្ខណៈភូមិសាស្ត្រ ល្អសំរាប់ប្រជាពលរដ្ឋរស់នៅ ងាយស្រួលធ្វើផ្លូវមានប្រភពទឹកប្រើប្រាស់ និង ងាយចតទូកសំរាប់គ្រួសារមានមុខរបរនេសាទ ។

-ក្នុងការពង្រីកដីស្រែរបស់ឃុំត្រពាំងរូងគឺ ត្រូវចាប់អារម្មណ៍ទៅលើវាលស្រែដែលបានបោះបង់ចោលក្លាយទៅជាវាលស្មៅដុះដើមស្នាច់មួយៗ ដែលក្នុងនោះតាមគោលការណ៍ដែលឃុំបានគិតគូរសំរាប់ការពង្រីកដីស្រែ

១៨៣.៣៨ ហិកតា មាន ០៣ កន្លែង :

១-នៅចំណុចវាលស្បូវក្នុងភូមិត្រពាំងរូងមានទំហំប្រមាណ ៦០ ហិចតា ដែលមានលេខកូដ F2110-01 កន្លែងនេះជាដីស្រែចាស់មានប្រព័ន្ធភ្លឺស្រែស្រាប់មិនប៉ះពាល់ដល់ធនធានធម្មជាតិឡើយ ។

២-នៅចំណុចក្បែរភ្នំលោកឃុំមានគំរោងពង្រីកផ្ទៃដីស្រែបន្ថែមសំរាប់រយៈពេល ១៥ ឆ្នាំ មានទំហំប្រមាណ ៤០ ហិកតា ដែលមានលេខកូដ F2110-02 ជាដីស្រែចាស់មានដុះស្មៅដើមស្នាច់មួយៗ

បច្ចុប្បន្ន ដីនេះស្ថិតក្នុងតំបន់ការពារ ហើយដីនេះមានលក្ខណៈ ភូមិសាស្ត្រអំណោយផលល្អព្រោះទីនេះជិតភូមិករស្រាប់ ឯផលប៉ះពាល់ដល់ធនធានធម្មជាតិក៏មានតិចតួចដែរ ។

៣-នៅភូមិកោះកុងក្នុងឃុំមានគម្រោងពង្រីដីស្រែបន្ថែម ទំហំប្រមាណ ៨៣ ហិកតា ដែលមានលេខកូដ F2110-03 សំរាប់រយៈពេល១៥ឆ្នាំ ផងដែរ ព្រោះទីនោះភាគច្រើនជាដីស្រែចាស់ពីមុនមកតែពេលឥឡូវវាដុះដើមស្នាច់មួយៗម្យ៉ាងវិញទៀតទីនេះនៅខាងក្រោយភូមិស្រាប់ដែលមានចំងាយប្រមាណ ២០០ ម ពីមាត់ព្រែក ។

-ដីចំការដំណាំមាន០២កន្លែងហើយរយៈពេល ១៥ ឆ្នាំ ខាងមុខត្រូវការពង្រីកដីប្រភេទនេះជាការគិតគូរឱ្យបានត្រឹមត្រូវផងដែរ ទៅលើការពង្រីកនេះជាគោលការណ៍ឃុំបានកំណត់ប្រភេទដីទួលជិតភូមិដីខ្លះទៀត នៅពីក្រោយភូមិករស្រាប់ដែលអាចមានលទ្ធភាពក្នុងការ ដាំដំណាំគ្រប់ប្រភេទបានក្នុងនោះពង្រីកដីចំនួន ៣២៩.៤៥ ហិកតា នៅភូមិដីទំនាបចំណុចភ្នំលោក និង នៅភូមិព្រែកអង្គុញ ។

-នៅភូមិដីទំនាប (ចំណុចភ្នំលោក ) មានទំហំប្រមាណ ២០០ ហិកតា ដែលមានលេខកូដ F2310-01 ទីនេះជាព្រៃរេចរឹលជាទីទួលក្បែរភូមិ មានប្រភពងាយស្រួលដល់ដំណាំចំការ ។

-នៅភូមិព្រែកអង្គុញមានទំហំប្រមាណ ១២៩.៤៥ ហិកតា ដែលមានលេខកូដ F2310-02 នៅខាងក្រោយភូមិមានចំងាយពីមាត់ព្រែកប្រមាណ ៤០០ ម ជាដីព្រៃរបោះមានដើមស្នាច់មួយៗកន្លែងខ្លះជាដីចំការចាស់ ស្រែចាស់ ។

-បញ្ហាផ្ទៃបឹងឃុំមានការស្តារបឹងធម្មជាតិសំរាប់ប្រើប្រាស់ប្រយោជន៏រួម ដែលមានលេខកូដ F5111-01 ។ ដូច្នេះដីផ្ទៃទឹកមាននៅក្នុងឃុំមិន អាចកែប្រែ ឬកែសំរួលឱ្យក្លាយជាប្រយោជន៏ក្រៅពីប្រភពទឹក និង សំរាប់ប្រើប្រាស់ស្រោចស្រព និងអភិរក្សមច្ឆាជាតិ សំរាប់ឃុំឡើយ ។

-ផ្ទៃដីចំការព្រៃដាំកសិកម្មពនេចរ ចំការចន្ទី ចំការឈើហូបផ្លែដីភូមិចាស់ ល្បាយដីព្រៃលាយដីស្រែ ល្បាយដីព្រៃលាយដីចំការ ព្រៃស្រោង ដីគ្មានរុក្ខជាតិដុះគ្របដណ្តប់ ព្រៃកាប់ឆ្ការ ព្រៃចំរុះ (ក្រាស់ ស្តើង )ព្រៃដុះឡើងវិញ ព្រៃឬស្សី ព្រៃលិចទឹក (ក្រាស់ ស្តើង) កោងកាង វាលស្មៅ ចំការបោះបង់ចោលដុះស្មៅ វាលស្មៅលិចទឹក ព្រៃកុម្ពោត ព្រៃកុម្ពោតលាយដើមឈើធំមួយៗ ផ្ទៃបឹងសមុទ្រ ស្រែបង្គា រាល់ចំណុចទាំងនេះជាតំបន់ការពារ ។ តែតំរូវការប្រើប្រាស់ដីពេលអនាគតសំរាប់បង្កើតភូមិដីស្រែ ដីចំការឈើហូបផ្លែ សរុបទាំងអស់ ប្រមាណ ៥៩៥ ហិកតា ។

ដូច្នេះតំបន់ការពារធនធានធម្មជាតិមានការថយចុះបន្តិចបន្តួច ។

-ព្រៃសហគមន៏នៅក្នុងឃុំត្រពាំងរូងបច្ចុប្បន្នការប្រើប្រាស់ឈើសំរាប់សង់លំនៅដ្ឋាន និង ធ្វើអ្វីផ្សេងៗក្នុងការប្រើប្រាស់ប្រចាំគ្រួសារមានការលំបាកព្រោះកន្លែងព្រៃឈើទាំងអស់នោះ ស្ថិតនៅក្នុងដែនរដ្ឋបាលព្រៃឈើ និង ឧទ្យានជាតិបូទុមសាគរក្រោមការការពាររបស់អង្គការវ៉ាយអេដ ។ អាស្រ័យហេតុនេះដើម្បីបំរើផលប្រយោជន៏ដល់ប្រជាពលរដ្ឋ និង ដើម្បីរក្សានូវធនធានព្រៃឈើឱ្យមាននិរន្តរភាពផងនោះ ឃុំបានកំណត់ព្រៃសំរាប់សហគមន៏មួយកន្លែងស្ថិតនៅក្នុង ភូមិដីទំនាប និងនៅភូមិព្រែកអង្គុញដែលមានទំហំប្រមាណ ២៧០ ហិកតា ដែលមានលេខកូដ F3710-01 ។ កន្លែងនេះជាព្រៃស្រោង និង មានឈើគ្រប់ ប្រភេទអាចយកឈើមកប្រើប្រាស់ក្នុងសហគមន៏បាន ។

-ដោយមានគោលនយោបាយពីរាជរដ្ឋាភិបាល ក្នុងការបែងចែកដីធ្លីជូនដល់ប្រជាពលរដ្ឋទីទាល់ក្រ និង យោធិនរំសាយ ក៏ដូចជាគ្រួសារយោធិនពលី ពិការ ឃុំបានត្រៀមបំរុងដីសម្បទានសង្គមកិច្ចចំនួន ៨៥០ ហិកតា ដែលមានលេខកូដ F6700-01 ដែលស្ថិតនៅក្នុងភូមិកោះកុងក្នុង។

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រងនិងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវ ផលប្រយោជន៏ និង មាននិរន្តរភាពហើយនឹងមានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និង បរិស្ថាន ដែល ក្នុងនោះមានដូចជា :

ការប្រែប្រួលពី ដីវាលស្មៅ ដីស្រែចាស់បោះបង់ចោល ទៅជាដីស្រែសំរាប់ការបង្កបង្កើនផលនេះជាការពង្រីក លើវិស័យកសិកម្ម វាជាកត្តាអំណោយផល ដល់ការបង្កើននូវផលិតផល ក៏ដូចជា សេដ្ឋកិច្ច ក្នុងមូលដ្ឋាន។ នៅក្នុងបរិបទនេះការប្រែប្រួលប្រភេទដី ប្រសិនបើវាលស្មៅដែលជាដីស្រែដែលត្រូវបោះបង់ចោលនោះវាជាមោទនៈ ភាពសំរាប់ការពង្រីកលើ ការងារធ្វើស្រែ។

ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងមូលដ្ឋានឃុំ គឺជាកត្តាផ្តល់នូវផលប្រយោជន៏យ៉ាងច្រើនដល់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា :

- ការសាងសង់ផ្លូវ គឺជាការសំរួលដល់ការធ្វើដំណើរ និង ចរាចរណ៏គ្រប់ប្រភេទ ហើយនិងចូលរួមក្នុងការ កាត់បន្ថយការចំណាយទៅលើការងារដឹកជញ្ជូន ។ ការអភិវឌ្ឍន៏នេះថ្វីត្បិតតែមានការដោះស្រាយ និង ហេតុប៉ះពាល់ ខ្លះៗក៏ដោយប៉ុន្តែវាផ្តល់នូវផលប្រយោជន៏ច្រើនដល់ប្រជាជនប្រើប្រាស់ ។

-ការស្តារបឹងធម្មជាតិ ដើម្បីធានាដល់ការស្រោចស្រពក៏ដូចជាកត្តាផ្តល់នូវសារៈប្រយោជន៏ ក្នុងការបង្កើន នូវប្រាក់ចំណូលតាមរយៈការបង្កបង្កើនផល និង ដំណាំរួមផ្សំ ។ នៅក្នុងឃុំត្រពាំងរូងតម្រូវការប្រើប្រាស់ទឹកសំរាប់ ស្រោចស្រពគឺជាកត្តាសំខាន់ថ្វីត្បិតតែការស្តារពង្រីកបឹងសំរាប់ស្រោចស្រពនេះជួបការលំបាកយ៉ាងណាក៏ដោយ ក៏ឃុំនៅ តែព្យាយាមរកវិធីសាស្រ្តដោះស្រាយ និង ជំរុញអោយមាននិរន្តរភាពលើការងារនេះ ។

ដោយឡែកចំពោះការពង្រីកវិស័យអប់រំ ដោយផ្តោតទៅលើ ការពង្រីកអគារសិក្សា និង សាលា គឺជាការ ចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន ។ បច្ចុប្បន្នទោះបីឃុំមានការខ្វះខាតដីសំរាប់បង្កើត សាលាថ្មីសំរាប់ថ្នាក់បឋមសិក្សា និង អនុវិទ្យាល័យ ប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់ នៅមានដីដែលអាចសាង សង់អគារសិក្សា បន្ថែមបាន។ រីឯសាលាមត្តេយ្យ ដោយមើលឃើញការលំបាកសំរាប់កុមារដែលមានអាយុក្រោម ៥ ឆ្នាំគ្មានសាលាឃុំត្រូវព្យាយាមរកដំណោះស្រាយអោយបាននៅក្នុងឃុំ ព្រោះវាមានសារៈសំខាន់និង ជាមូលដ្ឋាន គ្រឹះនៃការបណ្តុះបណ្តាល និង ការបំពាក់បំប៉នចំណេះដឹង ដល់អក្ខរៈជន ក្នុងមូលដ្ឋាន ។

## ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត




## ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុងឃុំត្រពាំងរូងត្រូវបានបែងចែក ទៅតាមគោលការណ៍មួយចំនួន ដែលមានលក្ខណៈជាសត្យានុម័ត ហើយបានអនុលោមទៅតាមមុខនាទីដូចខាងក្រោម :

- ការប្រើប្រាស់សំរាប់ដីលំនៅដ្ឋាន ឬ ដីភូមិ គឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋានដោយមានការដាំដំណាំ រួមផ្សំ ដូចជា ដូង ស្វាយ ខ្នុរ មង្ឃុត ធុរេន ។

- នៅក្នុងការប្រែប្រួលនូវប្រភេទដីពីដីភូមិចាស់ ដីចំការបោះបង់ចោលមកជាដីលំនៅដ្ឋានគ្រួសាររបស់ប្រជាពលរដ្ឋដោយការបែងចែកកេរ្តិ៍ទុកអោយកូន ។ រីឯស្ថានភាពនៃការរីករាលដាលសំរាប់ប្រភេទដីលំនៅដ្ឋាននេះ គឺភាគច្រើនរីកតាមបណ្តោយផ្លូវលេខជាតិ ៤៨ ឬតាមបណ្តោយមាត់ព្រែក ។

- ការប្រើប្រាស់ដីសំរាប់ដីស្រែនៅក្នុងឃុំត្រពាំងរូងវាមានតែមួយប្រភេទប៉ុណ្ណោះគឺស្រែវស្សា ។

ការប្រែប្រួលក៏ដូចជាការកើនឡើងនៃប្រភេទដីស្រែនេះ គឺជាការពង្រីកទៅលើដីវាលស្មៅ ស្រែចាស់ដែលបានបោះបង់ចោលពីមុនមកនោះត្រូវបានធ្វើការរៀបចំកែលំអឡើងវិញដោយធ្វើការកែលំអទៅតាមលក្ខណៈបច្ចេកទេសកសិកម្មដំណាំស្រូវដល់ប្រជាពលរដ្ឋ ដើម្បីផ្តល់ឱកាសដល់ពួកគាត់ចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន ។ សូមបញ្ជាក់ផងដែរថាដីស្រែចាស់ទាំងនេះបច្ចុប្បន្នជាដីវាលដុះស្មៅ និង កន្លែងខ្លះទៀតដុះដើមស្នាច់លាយ

ស្មៅតែវាមិនប៉ះពាល់ដល់ធនធានធម្មជាតិប៉ុន្មានឡើយ ការប្រើប្រាស់ដីព្រៃរេចរឹល ព្រៃរបោះ ចំការចាស់ មកជាដីចំការដំណាំសំរាប់តំរូវការអនាគតនោះ ភាគច្រើនជាដីដែលបានគ្រោងនោះ ច្រើននៅជាប់នឹងដីភូមិ និង ជិតភូមិស្រាប់

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណៈរបស់រដ្ឋ )គឺត្រូវទាមទារអោយមានការថែរក្សាអោយបានគង់វង្ស ដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការ ការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍន៏ទៅលើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៏ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

- ការប្រើប្រាស់ដីផ្ទៃទឹកនានានៅក្នុងឃុំ គឺ ជាកត្តាចំបងសំរាប់ប្រជាជនក្នុងមូលដ្ឋានដើម្បីបំរើផលប្រយោជន៏អោយវិស័យកសិកម្ម និង ការប្រើប្រាស់ទូទៅផ្អែកតាមធនធានទឹកដែលមានក្នុងឃុំ ។ ឃុំអាចមានលទ្ធភាពក្នុងការដកយកមកប្រើប្រាស់បានតែប្រភេទទឹកព្រែក និង បឹងតែប៉ុណ្ណោះ (ព្រែកប្រើបានតែរដូវវស្សា ) ។

- កាប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយបានព្រោះថាផ្លូវដែលកើតឡើងគឺជាការផ្តើមចេញពីប្រជាជនផ្ទាល់ដែលជាអ្នកធ្វើអោយកើតមានផ្លូវជាដំបូង ហើយឃុំក៏លើកគម្រោងអភិវឌ្ឍន៏ទៅតាមការស្នើរឡើងពីសំណាក់ប្រជាពលរដ្ឋ។ បច្ចុប្បន្នការអភិវឌ្ឍន៏ទៅលើហេដ្ឋារចនាសម្ពន្ធ័ ផ្លូវថ្នល់ក្នុងឃុំគឺអនុវត្តទៅលើផ្លូវចាស់មានស្រាប់ ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន ។

### ៣.២.៣.១ ដីលំនៅដ្ឋាន ( បញ្ញត្តិគោលការណ៍នៃការប្រើប្រាស់ដី )

តាមស្ថានភាពជាក់ស្តែងដែលបានគ្រោងទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋ ១៦៤គ្រួសារបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋានចំនួន ១៥៤ គ្រួសារ សំរាប់រយៈពេល ១៥ឆ្នាំ ប៉ុន្តែនៅក្នុងការគិតគូរទៅលើការកំណត់ផ្ទៃដីភូមិក្នុងមួយគ្រួសារ 0.៣៦ ហិកតា នោះឃុំអាចមានលទ្ធភាពបំពេញតំរូវការដីបាន ១១៤.៤៨ ហិកតាសំរាប់ប្រជាពលរដ្ឋកំណើន ១៦៤ គ្រួសារ និង ១៥៤គ្រួសារ មិនទាន់មានដីលំនៅដ្ឋាន ។ ដូច្នេះការកំណើនតំរូវការដីភូមិក្នុង១គ្រួសារអាចបាន 0.៣៦ ហិកតា (យោងអនុក្រឹត្យលេខ:១៩ អ ន ក្រ .បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២00៣) ដោយផ្អែកលើផ្ទៃដីដែលបានគ្រោង ១១៤.៤៨ ហិកតា ហើយត្រូវបានកំណត់លើការបែងចែក និង អភិវឌ្ឍទៅតាមតំបន់គោលដៅដូចខាងក្រោម :

-ទីតាំងលេខកូដ : F 1200-01

នៅក្នុងភូមិត្រពាំងរូង (ចំណុចវាលស្បូវ ) ដែលមានលេខកូដ F 1200-01 ត្រូវបានកំណត់លើការពង្រីកដីលំនៅដ្ឋានដែលមានទំហំ ៤0 ហិកតា ដែលក្នុងនោះគ្រោងសំរាប់ប្រជាពលរដ្ឋចំនួន ១១១គ្រួសារ ហើយអនុវត្តសំរាប់រយៈពេល៥ឆ្នាំទី១ចំនួន ៤0 ហិកតា សំរាប់ប្រជាពលរដ្ឋ ១១១គ្រួសារ (ប្រភេទនៃការបែងចែកត្រូវបានកំណត់ក្បាលដី ៣0ម x ១២0ម ) តាមការកំណត់នេះ គឺត្រូវបានគិតគូរផ្អែកតាមបណ្តោយផ្លូវដែលបានគ្រោង និង ធ្វើការសាងសង់ ។

-ទីតាំងលេខកូដ: F 1200-02

នៅឃុំត្រពាំងរូង (ចំណុចព្រៃកបើស) ដែលមានលេខកូដ F 1200-02 ត្រូវបានកំណត់លើការពង្រីកដីលំនៅដ្ឋាននៅតាមបណ្តោយមាត់ព្រែក និង តាមផ្លូវលំដែលមានទំហំ ៧៤.៤៨ ហិកតា និង ត្រូវបានកំណត់លើប្រជាពលរដ្ឋសំរាប់អនុវត្តឆ្នាំទី១ ចំនួន ៣២.៤០ហិកតា សំរាប់ប្រជាពលរដ្ឋចំនួន ៩០គ្រួសារ អនុវត្តឆ្នាំទី២ ចំនួន ២០.៨៤ ហិកតា សំរាប់ប្រជាពលរដ្ឋ ៥៨ គ្រួសារ និង អនុវត្តឆ្នាំទី៣ ចំនួន ២១.២៤ ហិកតា លើចំនួន ៥៩ គ្រួសារ (ប្រភេទនៃការបែងចែកត្រូវបានកំណត់លើក្បាលដី ៣០ម x ១២០ម) នៅតាមមាត់ព្រែក និង តាមផ្លូវលំ ។

នៅក្នុងការប្រែប្រួលនូវប្រភេទដីពីចំការភូមិចាស់ដីវាលស្មៅ មកជាដីលំនៅដ្ឋានតាមរយៈនៃការរីករាលដាលនៃគ្រួសាររបស់ប្រជាពលរដ្ឋ ដោយការបែងចែកកេរ្តិ៍ទុកអោយកូន និង ការលក់ដោះដូរជាប្រាក់ លើដីដែលមានការកាន់កាប់មួយចំនួនក្រៅពីនោះ ជាទ្រព្យសាធារណៈរបស់រដ្ឋ សំរាប់ធ្វើការបែងចែកដល់ប្រជាពលរដ្ឋសង់លំនៅដ្ឋាន ឬ ជាដីភូមិ ។ រីឯស្ថានភាពរីករាលដាល សំរាប់ប្រភេទដីលំនៅដ្ឋាននេះ គឺភាគច្រើនរីកតាមបណ្តោយផ្លូវតាមបណ្តោយមាត់ព្រែក ឬ តាមប្រភពទឹកផ្សេងៗ។ ការបង្កើតលំនៅដ្ឋានថ្មីតូចឬធំទៅតាមស្ថានភាពដីដែលឪពុកម្តាយចែកអោយ ឬ បានមកពីការបែងចែកពីរដ្ឋអំណាចមូលដ្ឋាន ។

**បញ្ញត្តិការប្រើប្រាស់សំរាប់សង់លំនៅដ្ឋានថ្មីគឺ :**

នៅក្នុងការពង្រីកដីលំនៅដ្ឋានឃុំមានគោលការណ៍រៀបចំដីភូមិដែលមានការកំណត់ និង ជំរុញអោយមានដីភូមិដែលមានសណ្តាប់ធ្នាប់សាធារណៈល្អហើយក្នុងនោះត្រូវបានអនុវត្ត :

-រាល់ដីភូមិដែលត្រូវរៀបចំថ្មី ត្រូវបានកំណត់ទុកដីចំណីផ្លូវស្របតាមច្បាប់កំណត់

-ចំពោះដីភូមិដែលត្រូវរៀបចំថ្មីនៅតាមមាត់ព្រែក ឬ អូរតាមការកំណត់នៃច្បាប់

-ការសាងសង់លំនៅដ្ឋានថ្មី នៅក្បែរដីព្រៃការពារត្រូវចេះជួយថែរក្សានូវធនធានធម្មជាតិទាំងឡាយដែលមាននៅក្នុងព្រៃ

-ការសាងសង់លំនៅដ្ឋានក្នុងភូមិត្រូវអនុវត្តទៅតាមច្បាប់អនុញ្ញាត

-ជំរៅដីសំរាប់លំនៅដ្ឋានមិនអាចលើសពី១២០មគិតពីអ័ក្សផ្លូវ

-មិនត្រូវសង់លំនៅដ្ឋានលើដីសាធារណៈរបស់រដ្ឋជាដាច់ខាត

-រាល់ដីភូមិដែលកើតថ្មី ត្រូវមានការកំណត់ព្រំប្រទល់ដោយមានការឯកភាពរវាងភាគីពាក់ព័ន្ធហើយត្រូវបានបោះបង្គោលរបងកំណត់ព្រំច្បាស់លាស់ ។

**-ដីកសិកម្មមានទីតាំងលេខកូដ :** F2110-01/ F2110-02/ F2110-03/ F2310-01/ F2310-02

ដីចំការដំណាំនៅក្នុងឃុំបានគ្រោងដីដែលមានទីតាំងនៅភូមិដីទំនាប (ចំណុចភ្នំលោក) ទំហំ ២០០ ហិកតា និង ភូមិព្រៃកអង្កុញ ១២៩.៤៥ ហិកតា សរុប **៣២៩.៤៥** ហិកតា និង គ្រោងដីស្រែនៅភូមិត្រពាំងរូង ( ចំណុចវាលស្បូវ ) ទំហំ ប្រមាណ ៦០ ហិកតា នៅភូមិដីទំនាប(ចំណុចភ្នំលោក) ទំហំប្រមាណ ៤០ ហិកតា និង នៅភូមិកោះកុងក្នុងទំហំប្រមាណ ៨២.៦៩ ហិកតា ដីស្រែសរុប **១៨៣.៣៨**ហិកតា ។

នៅឃុំត្រពាំងរូងត្រូវបានកំណត់លើការងារពង្រីកដីស្រែ និងដីចំការ ដែលមានទំហំ ៩១២.៨៣ហិកតា ត្រូវបាន កំណត់លើប្រជាពលរដ្ឋ ១៣៧ គ្រួសារ នៅ៥ឆ្នាំទី១ឃុំ គ្រោងដីមានទំហំ ៣៨៥ ហិកតា សំរាប់ចំនួន ៩២ គ្រួសារ ៥ឆ្នាំទី២ មានទំហំ ៧៨.៥៤ ហិកតា សំរាប់ចំនួន ២១គ្រួសារ និងគ្រោង៥ឆ្នាំទី៣មានទំហំ ៨៦.០២ ហិកតា សំរាប់ចំនួន ២៣ គ្រួសារ ។

ប្រភេទនៃការបែងចែកត្រូវបានកំណត់ក្បាលដី (១៥០ម x ២៥០ម) នៅសងខាងផ្លូវលំដែលបានគ្រោង ។

សូមបញ្ជាក់ថា : តម្រូវការដីក្នុងដីសម្បទានសង្គមកិច្ចសំរាប់គ្រោងបន្ថែមលើដីដែលបានគ្រោងដីសម្បទានសង្គមកិច្ចចែកជូនប្រជាពលរដ្ឋនៅពេលអនាគតឆ្នាំ២០២២ខាងមុខ ។

-បន្ថែមដីស្រែមានទំហំ ៧១.២៤ ហិកតា សំរាប់ប្រជាពលរដ្ឋ១៩គ្រួសារ

-ដីចំការដំណាំមានទំហំ ៣៧១.២១ ហិកតា សំរាប់ប្រជាពលរដ្ឋ៩៩គ្រួសារ សរុបទាំងដីស្រែ នឹងដីចំការដំណាំ មានទំហំ ៤៤២.៤៦ហិកតា ដូច្នេះដីសម្បទានដែលឃុំបានគ្រោងទុក ៨៥០ហិកតា នៅសល់៤០៧.៥៥ហិកតា ។

**គោលការណ៍នៃការប្រើប្រាស់ដីកសិកម្ម**

-នៅក្នុងកិច្ចអភិវឌ្ឍន៏សំរាប់ពេលអនាគតឃុំ មានគោលការណ៍ក្នុងការរៀបចំនៅការបង្កីនផលិតកម្មដំណាំស្រូវ ដែលក្នុងនោះត្រូវអនុវត្តនូវយុទ្ធសាស្ត្រមួយចំនួនដែលអាចជួយដល់ការបង្កើនផលិតភាពកសិកម្មគឺ :

-លើកភ្លឺដើម្បីរក្សាទឹកនៅរដូវវស្សា
-លើកកំពស់ការប្រើប្រាស់ជីធម្មជាតិ ជីកំប៉ុស្តិ៍
-កាត់បន្ថយការប្រើប្រាស់ជីគីមី
-កាត់បន្ថយការប្រើថ្នាំពុលជំរុញការអនុវត្តន៏កម្មវិធី IPM
-រៀបចំប្រពលវប្បកម្មដំណាំស្រូវ (ប វ ស)
-អភិវឌ្ឍលើការស្តារដីស្រែចាស់អោយអស់នូវផ្ទៃដីស្រែដែលមាន
-បង្កើនការដាំណាំចំការគ្រប់ប្រភេទ ដើម្បីអោយការប្រើប្រាស់មានប្រសិទ្ធភាពឃុំបានកំណត់ដូចខាងក្រោម :
-ហាមដាច់ខាតការពង្រីកដីលើដីសាធារណៈរបស់រដ្ឋ
-ហាមឃាត់ដាច់ខាតការវាតដីស្រែចូលបឹង ឬ ប្រឡាយ
-ហាមឃាត់ដាច់ខាតការកាប់រានចូលដីនាទីព្រៃលិចទឹកដើម្បីធ្វើស្រែ
-រាល់ដីស្រែត្រូវមានភ្លឺសំរាប់សំគាល់ព្រំប្រទល់ច្បាស់លាស់
-ហាមការប្រើប្រាស់ថ្នាំពុលលើដីស្រែដែលអាចប៉ះពាល់ដល់ធនធានធម្មជាតិ

**៣.២.៣.២ ការប្រើប្រាស់ទឹក និង ប្រព័ន្ធស្រោចស្រព**

ការប្រើប្រាស់ដីផ្ទៃទឹកនានានៅក្នុងឃុំគឺជាកត្តាចំបងសំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដើម្បី បំរើផលប្រយោជន៏អោយវិស័យកសិកម្ម និង ការប្រើប្រាស់ទូទៅផ្នែកតាមធនធានទឹកដែលមានក្នុងឃុំអាចមានលទ្ធិភាពក្នុងការដកយកមកប្រើប្រាស់បានតែប្រភេទទឹកអណ្តូង និង ស្រះតែប៉ុណ្ណោះ ។

### ៣.២.៣.៣ ការប្រើប្រាស់ផ្លូវថ្នល់

ការប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរប៉ុន្តែអាចដោះស្រាយបាន ព្រោះថាផ្លូវដែលកើតឡើងគឺចេញពីប្រជាជនផ្ទាល់ដែលជាអ្នកធ្វើអោយកើតមានផ្លូវជាដំបូង ហើយឃុំក៏លើកគំរោងអភិវឌ្ឍទៅតាមកាស្នើឡើងពីសំណាក់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នការអភិវឌ្ឍន៏ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងឃុំគឺអនុវត្តទៅលើផ្លូវចាស់មានស្រាប់ដូច្នេះ ដំណោះស្រាយអាចដោះស្រាយបាន ។

### ៣.២.៣.៤ ទីតាំងផ្លូវក្រាលគ្រួសក្រហម

នៅក្នុងកិច្ចអភិវឌ្ឍន៏លើផ្លូវថ្នល់ក្រាលគ្រួសក្រហមចំនួន៩ខ្សែមានប្រវែង ២៥,៨០៤ ម ឃុំធ្វើការកំណត់ជាដំណាក់កាល៥ឆ្នាំទី១សាងសង់ផ្លូវគ្រួសក្របាហមប្រវែង ១១,៦០៣ ម ស្ថិតក្នុងភូមិត្រពាំងរូង៥ឆ្នាំទី២ សាងសង់ផ្លូវគ្រួសក្របាហមប្រវែង ៨,៧៥៣ ម ស្ថិតក្នុងភូមិព្រែកអង្កុញ៥ឆ្នាំទី៣សាងសង់ផ្លូវគ្រួសក្របាហមប្រវែង ៨,៧៥៣ ម ស្ថិតនៅក្នុងភូមិដីទំនាប ។

### បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ផ្លូវថ្នល់

ក្នុងលក្ខណៈបច្ចេកទេសនៃការសាងសង់ផ្លូវត្រូវបានកំណត់សំរាប់ផ្លូវដូចខាងក្រោម :

-ផ្លូវក្រាលគ្រួសក្របាហមក្នុងក្របខ័ណ្ឌមូលដ្ឋានឃុំត្រូវទុកដីចំណីផ្លូវ ៧ ម សងខាងផ្លូវ

-ការកំណត់លើការប្រើប្រាស់ផ្លូវថ្នល់ត្រូវអនុលោមទៅតាមច្បាប់

-បង្កើតសហគមន៏ថែទាំផ្លូវដោយមានចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន

-ហាមការដឹកជញ្ជូនលើសទំងន់

-ហាមការយក គោ ក្របី ជ្រូក ចងលើផ្លូវ

-រៀបចំស្លាកសញ្ញាចរាចរណ៏តាមបណ្ដោយផ្លូវ

### ៣.២.៣.៥ ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់

នៅក្នុងឃុំត្រពាំងរូងដោយតម្រូវការអគារសិក្សាសំរាប់សាលាបឋមសិក្សា និង វិទ្យាល័យត្រូវបានគ្រោងបង្កើតសាលា និង សាងសង់អគារបន្ថែមដែលក្នុងនោះមាន :

-សាលាបឋមសសិក្សាគ្រោងសាងសង់មួយអគារក្នុងភូមិកោះកុងក្នុងនៅ៥ឆ្នាំទី៣

-សាលាវិទ្យាល័យគ្រោងសាងសង់មួយអគារក្នុងភូមិត្រពាំងរូងនៅ៥ឆ្នាំទី២

-សំរាប់អគារដែលត្រូវសាងសង់កំណត់មួយអគារ៥បន្ទប់បឋមសិក្សា និង វិទ្យាល័យម្យ៉ាងវិញទៀតប្រសិនបើក្នុងករណីមានការគាំទ្រណាមួយដែលមានលទ្ធភាពក្នុងការសាងសង់អគារមួយខ្នងពីរជាន់១០បន្ទប់នោះកាន់តែល្អហើយ ឃុំ និង មានការគាំទ្រជានិច្ច ។

### ៣.២.៣.៦ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន

-ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណៈរបស់រដ្ឋ)គឺត្រូវទាមទារអោយការថែរក្សាអោយបានគង់វង្សដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារថែរក្សាអភិរក្ស និង អភិវឌ្ឍទៅលើធនធាន

ទាំងនោះ ដើម្បីផ្តល់នូវផលប្រយោជន៍ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តភាព ។

នៅក្នុងការប្រែប្រួលដីវាលស្មៅទៅជាដីដែលមានព្រៃលិចទឹកនោះ គឺជាអាទិភាពដោយសារដីប្រភេទវាលស្មៅដែលស្ថិតក្នុងនាទីព្រៃលិចទឹកគឺដីព្រៃលិចទឹកដែលបានឆេះ កន្លងមកក្លាយជាវាលស្មៅដូច្នេះជាគោលការណ៍ត្រូវការពារថែរក្សាទុកអោយព្រៃលិចទឹកដុះឡើងវិញដើម្បីធានាធនធានក្នុងតំបន់ ។

នៅក្នុងដំណើការនៃការការពារធនធានធម្មជាតិនៅឃុំត្រពាំងរូងត្រូវបានអនុវត្ត និង កំណត់ទៅតាមក្របខ័ណ្ឌនៃការទទួលខុសត្រូវលើការគ្រប់គ្រងរបស់ស្ថាប័នីមួយៗដូចជាឧទ្យានជាតិបូទុមសាគរដែលមានផ្ទៃក្រឡា១,៨៨២.៨៤ ហិកតា ។ ហើយជាមួយគ្នានេះដែរឃុំមាននាទីព្រៃលិចទឹកដែលជាជំរកដ៏ប្រសើរសំរាប់ធនធានជលផលដូច្នេះ ដើម្បីធានានូវសុវត្ថិភាពស្បៀង និង និរន្តរភាពធនធានធម្មជាតិក្នុងតំបន់ឃុំបានយកចិត្តទុកដាក់ចូលរួមការពារ និង ថែរក្សាអោយមានស្ថេរភាពយូរអង្វែង ។

-នៅក្នុងការការពារប្រភពធនធានជលផលដូចជាតំបន់ជំរកត្រីពងកូន

-កំណត់កន្លែងអភិរក្សព្រៃលិចទឹក ( ការពារថែរក្សាព្រៃលិចទឹក និង សត្វគ្រប់ប្រភេទ )

## បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ធនធាន

នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង និង ប្រើប្រាស់ធនធានឃុំត្រូវបានរៀបចំគ្រប់គ្រង និង ប្រើប្រាស់ទៅលើព្រៃលិចទឹកដែលក្នុងនោះត្រូវបែងចែក

-កំណត់ការដកយកផលអនុផលព្រៃឈើ និង ព្រៃលិចទឹក

-ហាមការចាប់សត្វព្រៃគ្រប់ប្រភេទនៅក្នុងដែនអភិរក្ស

-ហាមការចាប់សត្វដែលច្បាប់ជលផលបានកំណត់

-ហាមកាប់អុសក្នុងព្រៃអភិរក្ស និង ព្រៃលិចទឹក

-ហាមការកាប់រានដីព្រៃការពារ និង ព្រៃលិចទឹក

-ហាមការធ្វើស្រែក្នុងបឹង និង អូរ

-ហាមការបូមពង្រីងបឹងដើម្បីចាប់ត្រី

ឃុំត្រពាំងរូង,ថ្ងៃទី...12.....ខែ..........ឆ្នាំ ..2010..

**មេឃុំ**

ភាយ_អួយ

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវជ្ជខេត្តកោះកុង

"ដើម្បីមេត្តាពិនិត្យ និង សំរេច"

កោះកុង,ថ្ងៃទី...12.....ខែ..........ឆ្នាំ ..2010..

**អភិបាលនៃគណៈអភិបាលស្រុក**

**និង ប្រធានក្រុមការងារជីវជ្ជ**

**ស្រុកកោះកុង**

សោម_សុធីរ

[illegible]

**បានឃើញ និង ឯកភាព**

កោះកុង,ថ្ងៃទី.០៥.....ខែ..........ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវជ្ជ**

**ខេត្តកោះកុង**

**ប៊ុន លើក**

## ឧបសម្ព័ន្ធ ១

## ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅឋានភូមិ:**

**ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំ នៅក្នុងមូលដ្ឋានឃុំត្រពាំងរូងគឺជាដីស្ថិតនៅតាមដងផ្លូវជាតិលេខ ៤៨ និង នៅតាមមាត់ព្រែក។ នៅតាមដងផ្លូវជាតិជាដីខ្ពស់មិនងាយលិចទឹកជំនន់នៅរដូវវស្សា ឯនៅតាមមាត់ព្រែកជាទីទំនាបងាយលិចទឹកជំនន់នៅរដូវវស្សា កន្លែងនេះសួនដំណាំល្អគ្រប់ប្រភេទ ព្រោះទឹកជំនន់នាំយកដីល្បាប់មកជាមួយ ជាពិសេសដំណាំរួមផ្សំដូចជា ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ចេក ដូង ដំឡូង ស្វាយ ល្ហុត ខ្នុរ ........។ល។ ដីភូមិលាយសួនដំណាំភាគច្រើនជាដីស្ថិតនៅជាប់គ្នាតាមបណ្តោយផ្លូវជាតិលេខ ៤៨ និងនៅតាមសងខាងមាត់ព្រែកឃុំត្រពាំងរូង ។

តាមស្ថានភាពជាក់ស្តែងសួនដំណាំនៅតាមដងផ្លូវលេខ ៤៨ ជាដីទួលពិបាករកប្រភពទឹកនៅរដូវប្រាំង ដូចនេះដំណាំភាគច្រើនពុំសូវល្អដូចសួនដំណាំតាមមាត់ព្រែកដែលជាទីទំនាបដំណាំល្អ ខែវស្សាក៏ដូចជាខែ ប្រាំងពុំចាំបាច់ស្រោចទឹកក៏បាន ។

**ដីភូមិលាយស្រែ :**

ដីភូមិលាយស្រែ គឺជាដីភូមិដែលស្ថិតនៅដាច់ៗពីគ្នា ហើយនៅក្នុងរង្វង់ដីភូមិមានដីស្រែផ្នែកខាងក្រោយនៃដីភូមិ ។ ចំពោះដីស្រែប្រភេទនេះច្រើនមាននៅភូមិដីទំនាប ភូមិព្រែកអង្កុញ និង កោះកុងក្នុង ធ្វើបានតែរដូវវស្សាប៉ុណ្ណោះ ។ ស្រែដែលនៅក្នុងដីភូមិច្រើនមានទំហំតូចៗភាគច្រើនស្ថិតនៅខាងក្រោយនៃដីភូមិ ។ បន្ទាប់ពីធ្វើស្រែវស្សាដីទាំងនេះភាគច្រើននៅទំនេរមានតិចតួចដែលគេដាំដំណាំរដូវប្រាំងដូចជា ពោត ត្រកួន ដំឡូងជ្វា.....។ល។

- **ដីស្រែវស្សា :**

**ដីស្រែវស្សា ( ស្រូវសន្ទូង ) :**

ដីស្រែវស្សា នៅឃុំត្រពាំងរូងត្រូវបានប្រើប្រាស់ក្នុងការធ្វើស្រែបានតែមួយរដូវកាលប៉ុណ្ណោះព្រោះដីស្រែទាំងនោះមិនមានប្រភពទឹកឬអាងស្តុបទឹកឡើយ ធ្វើពឹងទៅលើទឹកភ្លៀងទាំងស្រុង ។ ពូជស្រូវដែលប្រើនៅទីនោះមាន ពូជស្រូវក្រហម ផ្កាម្លិះ រំដួល.....ទិន្នផលបាន ១ តោនទៅ ១.៥ តោនក្នុង១ហិកតា ។ ដីស្រែវស្សានៅក្នុងឃុំសរុបមាន ១៨៣.៣៤ ហិកតា តែធ្វើបានតែ ៤៦.៨ ហិកតាប៉ុណ្ណោះដោយកំលាំងអូសទាញ និង លទ្ធភាពស្តារដីស្រែឡើងវិញមានតិចតួច ។

+ចំការឈើហូបផ្លែ

ចំការឈើហូបផ្លែនៅឃុំត្រពាំងរូងសំបូរគួរសមច្រើនមាននៅលើដីទួល និង លើដីទំនាបមានប្រភពដំណាំដូចជា សាវម៉ាវ មង្ឃុត ធុរ៉េន កំពីងរាជ ក្រូចថ្លុង ក្រូចពោធិសាត់ ភ្សៀវ ។ល។ មួយឆ្នាំ ៗ ប្រជាជនលក់ដូរបានគួរសមជាពិសេសធុរេន មង្ឃុត ។ ចំការនៅលើដីទួលពិបាករកប្រភពទឹកមកស្រោចស្រពនៅរដូវប្រាំង ឯទីទំនាបដំណាំស្រស់បំព្រងស្មើរគ្រប់រដូវ ឯទិន្នផលក៏បានច្រើនជាងនៅលើដីទួលដែរ ។ ដីអំណោយផលចំពោះដំណាំប្រភេទទាំងនេះសព្វថ្ងៃប្រជាជនបានដាំបន្តបន្ទាប់ជាច្រើនដើម្បីលើកស្ទួយជីវភាពគ្រួសារទៅថ្ងៃអនាគត ។

+ចំការព្រៃដាំ

ចំការព្រៃដាំនៅឃុំត្រពាំងរូងមានតែពពួកដំណាំកាស្យាតែមួយមុខប៉ុណ្ណោះ ដំណាំទាំងនោះមានអាយុកាលប្រមាណ ៣-៤ ឆ្នាំ មកហើយលាតសន្ធឹងលើផ្ទៃដីប្រមាណ ២៤៣.៤៥ ហិកតា ឯណោះប្រភេទដំណាំទាំងនេះនៅដើមរដូវវស្សាវាផ្តល់នូវផ្សិតដែលជាម្ហូបមួយដ៏ល្អដូចផ្សិតស្នាច់ដែរ ។

+ដីកសិកម្មពនេចរ

កាលពីដើមឡើយនៅក្នុងឃុំត្រពាំងរូង ការធ្វើស្រូវចំការពនេចរជាប្រពៃណីទៅហើយគឺគេទំលាប់កាប់ព្រៃដាំស្រូវវិលជុំរាល់កន្លែងធ្លាប់បានធ្វើកន្លងមក ។ លុះដល់ពេលបច្ចុប្បន្នច្បាប់បានហាមឃាត់រាល់ការកាប់ព្រៃយកធ្វើចំការប្រភេទនេះឱ្យបង្វែរទិសមកធ្វើចំការអចិន្ត្រៃយ៍វិញ ចាប់ពីពេលនោះមកដីទាំងនោះភាគច្រើនទំនេរដែលមានទំហំប្រមាណ ២៧៧.៩៨ ហិកតា ឯណោះ ។

+ចំការស្វាយចន្ទី

នៅក្នុងឃុំត្រពាំងរូងអំឡុងឆ្នាំ ២០០៤-២០០៥ កាលនោះទីផ្សារគ្រាប់ស្វាយចន្ទីមានតំលៃគួរសម ១ គ.ក ស្មើ ២,៥០០៛ ទៅ ៣,០០០៛ ពេលនោះមានប្រជាជនមួយចំនួន បាននាំគ្នាដាំលើផ្ទៃដីសរុប ២៦.២៤ ហិកតា ។ តែពេលបច្ចុប្បន្នគ្រាប់ស្វាយចន្ទីហាក់ដូចជាគ្មានទីផ្សារដូចមុនឡើយ ។ តែទោះជាគ្មានទីផ្សារក៏ដោយអ្នកដែលមានចំការស្វាយចន្ទីទាំងនោះក៏មិនបង្វែរទិសដៅដាំអ្វីផ្សេងទៀតដែរ ។

+ចំការឈើហូបផ្លែលើដីភូមិចាស់

ឃុំត្រពាំងរូង ជាឃុំមួយមានតាំងពីសង្គមរាស្ត្រនិយមមកម្ល៉េះ សម័យកាលនោះប្រជាជនមានការរីកចំរើនជាពិសេសវិស័យកសិកម្ម ដូចជាដំណាំចំការឈើហូបផ្លែបានបន្សល់ទុករហូតមកដល់សព្វថ្ងៃដូចជា ខ្នុរ ស្វាយ កំពីងរាជ ធុរេន... ។ល។ ដីទាំងនោះមានទំហំប្រមាណ ៤៧.១០ ហិកតា ។

+ល្បាយដីព្រៃលាយដីស្រែ និង ល្បាយដីព្រៃលាយដីចំការ

នៅសម័យសង្គមរាស្ត្រនិយម នៅឃុំត្រពាំងរូងមានប្រជាពលរដ្ឋរស់នៅច្រើនដូចជាចំណុច កាឡុងតាកែវ កាឡុងស្វាយរៀង កាឡុងស្មគ្រចិត្ត កាឡុងកំពង់ចាម កន្លែងទាំងអស់នោះជាភូមិដ្ឋាន និង មានដីចំការ ដីស្រែ រាប់សិបហិកតា តែមកដល់បច្ចុប្បន្នកន្លែងទាំងនោះប្រែក្លាយទៅជាល្បាយដីព្រៃមួយដុះលាយនឹងដើមឈើហូបផ្លែដែលនៅសល់ដូចជា ខ្នុរ ទឹកដោះគោ ស្វាយ កំពីងរាជ.... ។ល។ ឯដីស្រែក៏ក្លាយទៅជាដីព្រៃស្នាច់មួយៗ ហើយស្រែ

មួយចំនួនតូចប្រជាពលរដ្ឋធ្វើបច្ចុប្បន្ន ។ ដីចំណុចទាំងនោះបច្ចុប្បន្នជាដីស្ថិតក្នុងតំបន់ការពាររបស់ឧទ្យានជាតិ និង រដ្ឋបាលព្រៃឈើ ។

+ព្រៃស្រោង

ដីនៅក្នុងឃុំត្រពាំងរូង ភាគច្រើនជាដីព្រៃការពារដូចនេះប្រភេទព្រៃជាព្រៃស្រោងសំបូរឈើធំៗដូចជា ដើមគគីរខ្សាច់ គគីរថ្ម ដើមផ្ចុង ឈើទាល ផ្ចៀត គ្រញូង ដូងថែម កំញាន សង្គមរមាស់ ដើមសាម៉ាស់ ដើមសំរ៉ង់ ឆាំឆា ។ល ។

+ដីគ្មានរុក្ខជាតិដុះគ្របដណ្តប់

ដីប្រភេទនេះមិនសូវជាមានប៉ុន្មានទេ របៀបដីជាំទឹកខ្សាច់មានថ្មដោយកន្លែង ដីនេះគ្មានរុក្ខជាតិដុះឡើយ ព្រោះខែវស្សាជាំទឹក ខែប្រាំងក្តៅខ្លាំង វាមានទំហំប្រមាណ ១.៣៧ ហិកតា ប៉ុណ្ណោះ ។

+ព្រៃកាប់ឆ្ការ

កាលពីមុននៅឃុំត្រពាំងរូងការកាប់ឆ្ការព្រៃយកដី និង កាប់ព្រៃអនាធិបតេយ្យកន្លងមកជាច្រើនដែល មានទំហំប្រមាណ៩៣.១៨ហិកតា បច្ចុប្បន្នដីទាំងនោះជាតំបន់ការពាររបស់ដែនរដ្ឋបាលព្រៃឈើ និង ឧទ្យានជាតិ ។

+ព្រៃចំរុះ( ស្តើង,រពោះ)

នៅឃុំត្រពាំងរូងជាតំបន់សំបូរព្រៃគ្រប់ប្រភេទ ដោយឡែកព្រៃចំរុះមាន តាត្រាវ ព្រីង ធ្លក តាសេក ស្នាច់ ខ្លុងត្បែង តាមូង តាមែង ត្របែកព្រៃ ល្បៀង ព្រុះ តាអោន ផ្កាវ ស្នាច់ដែង ។ល ។

+ព្រៃដុះឡើងវិញ

កាលសម័យអនាធិបតេយ្យនៅក្នុងឃុំត្រពាំងរូងកាប់ព្រៃឈើតូចធំគ្រប់ប្រភេទ កន្លែងខ្លះកាប់ខ្ទេចខ្ទីគ្មាន សល់លុះក្រោយមកច្បាប់បានរឹតបន្តឹងអំពីការកាប់បំផ្លាញព្រៃឈើ និង កាប់ព្រៃឈើយកដីលក់ជាដើម ។ ពេល ឥឡូវនេះកន្លែងទាំងនោះបានដុះព្រៃឡើងវិញលើទំហំដីប្រមាណ ៥,៤៧៦.៨៧ ហិកតា ។

+ព្រៃឫស្សី

នៅឃុំត្រពាំងរូងមានព្រៃកន្លែងខ្លះសុទ្ធតែព្រៃឫស្សីវាមានប្រយោជន៏ក្នុងការប្រើប្រាស់ផ្សេងៗ ទំពាំងជា អាហារ ដើមវាក៏ជាធនធានធម្មជាតិមួយដ៏ល្អសំរាប់ទេសចរធម្មជាតិផងដែរ ។

**+ដីព្រៃលិចទឹក :**

នៅក្នុងឃុំត្រពាំងរូងព្រៃលិចទឹកដែលមានផ្ទៃដី ៨៤០.៤៤ហិកតាសំបូរទៅដោយព្រៃឈើដូចជា ស្នាច់ ក្រញូប កោងកាង ដើមតាប៊ុន ............ វាផ្តល់នូវផលប្រយោជន៏ជាជំរកមច្ឆា និង វិស័យទេសចរធម្មជាតិ ។

+កោងកាង ( ក្រាស់ និង ស្តើង )

ចំណែកព្រៃកោងកាងនៅក្នុងឃុំត្រពាំងរូង លាតសន្ធឹងលើផ្ទៃដី ១,២៩៥.១១ ហិកតា ដែលដុះនៅជាប់ មាត់សមុទ្រ ក្នុងភូមិកោះកុងក្នុង ព្រៃកោងកាងមានផលប្រយោជន៏ណាស់ដូចជា ជំរកមច្ឆាជាតិ បំរើវិស័យទេសចរ និង សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ក្នុងសហគមន៏មូលដ្ឋាន ។

+ចំការបោះបង់ចោលដុះស្មៅ

នៅក្នុងអំឡុងឆ្នាំ ១៩៨៧-១៩៨៨ ឃុំត្រពាំងរូងប្រជាពលរដ្ឋភាគច្រើនកាប់ព្រៃដាំកញ្ឆា ដល់ឆ្នាំ ១៩៩១ ត្រូវបានច្បាប់ហាមឃាត់ក្នុងការផលិត និង ដាំកញ្ឆាជាប្រភេទគ្រឿងញៀន ។ តែបច្ចុប្បន្នដីទាំងនោះទុកចោលទំនេរ ដុះស្មៅដូចជា ស្បូវ ស្មៅកន្ទុយឆ្កែ ដែលមានផ្ទៃដីចំនួន ១៥៥.៨៤ ហិកតា សព្វថ្ងៃដីទាំងនោះស្ថិតក្នុងតំបន់ការពារ ។

+វាលស្មៅលិចទឹក

នៅក្នុងឃុំត្រពាំងរូង វាលស្មៅលិចទឹកសំបូរពពួកស្មៅ អញ្ចូត កក់ ស្មៅឆ្អឹងមាន់ ស្មាញ ស្មៅប្រភេទនេះមានផលប្រយោជន៍សំរាប់បំរើសេចក្តីត្រូវការរបស់របរប្រជាពលរដ្ឋដូចជា យកមកត្បាញធ្វើកន្ទេល និង ជាបន្លែ ។

+ព្រៃគុម្ពោត ព្រៃគុម្ពោតលាយដើមឈើធំមួយៗ :

តំបន់នេះជាប្រភេទដីរេចរឹលសំបូរដើម ពួច ញិញ គុយ ដើមធ្លក ចំបក់ តាសេក ព្រួស ស្វាច់........។ ដីប្រភេទនេះពុំសូវសំបូរជីជាតិឡើយ តែប្រភេទឈើខ្លះអាចយកមកធ្វើជាសំណង់បាន ។

+បឹង

បឹងនៅក្នុងឃុំត្រពាំងរូងភាគច្រើនរីងរាក់នៅរដូវប្រាំង តែរាល់បឹងនីមួយៗសំបូរទៅដោយត្រីទឹកសាបច្រើនប្រភេទដូចជា ត្រីរស់ ត្រីអណ្តែង ត្រីកន្ធរប់ ត្រីឆ្តោ អន្ទង់.....។ តែសព្វថ្ងៃនេះទោះជាអាជ្ញាធរខំប្រឹងទប់ស្កាត់រាល់បទល្មើសបំពុល និង ឆក់ត្រីយ៉ាងណាក៏ដោយ ក៏នៅមានប្រជាជនមួយក្តាប់តូចនៅតែលួចលាក់នេសាទខុសច្បាប់ដដែល តែនៅអនាគតជនទាំងនោះ និង យល់ពីច្បាប់ជលផលជាមិនខានឡើយ ។

+សមុទ្រ

នៅក្នុងឃុំត្រពាំងរូងមានជាប់ដែសមុទ្រ និង ព្រែកត្រពាំងរូង តែព្រែកនេះនៅរដូវវស្សាទឹកតាមព្រែកសាបដល់រដូវប្រាំងទឹកប្រៃ បើនិយាយពីមច្ឆាជាតិទាំងឡាយសំបូរគួរសមដូចជា ក្តាម ត្រីឆ្តុងស ត្រីតុកកែ ត្រីឆ្តុងក្រហម។ តែតាមព្រែកនៅរដូវវស្សាសំបូរដោយត្រីឆ្លាំង ត្រីកាហែ ត្រីក្ញាន់ ត្រីខ្មៅ ជាពិសេសបង្កង ។ ធនធានទាំងនេះមានការថយចុះបន្តិចម្តងៗព្រោះប្រជាពលរដ្ឋនៅតំបន់នេះក្រោយពីធ្វើស្រែវស្សារួច ភាគច្រើននេសាទ ។ នៅមានជនមួយក្តាប់តូចឆ្លៀតឱកាសប្រើប្រាស់នូវគ្រឿងឆក់ ថ្នាំបំពុល ជាហេតុធ្វើឱ្យធនធានទាំងនេះមានការថយបន្តិចម្តងៗ ។

+ស្រែចិញ្ចឹមបង្គា :

នៅក្នុងឃុំត្រពាំងរូងមានស្រែចិញ្ចឹមបង្គាមានតែភូមិកោះកុងក្នុងប៉ុណ្ណោះ ពេលបច្ចុប្បន្ននេះស្រែទាំងនោះលែងដំណើរការហើយ ។

| លរ | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| 1 |  Code : 1200<br>ដីលំនៅដ្ឋាន : ផ្ទះ-ទីសំណាប-ឈើហូបផ្លែ |  |
| 2 | Code : 2111<br>ដីភូមិលាយស្រែ |  |
| 3 |  Code : 2110<br>ស្រូវវស្សា : ធ្វើស្រែវស្សា |  |
| 4 | ចំការឈើហូបផ្លែ |  |

| | | |
|---|---|---|
| 5 | Code : 2324<br>ចំការព្រៃដាំ |  |
| 6 | Code : 2323<br>ចំការស្វាយចន្ទី |  |
| 7 | Code :<br>ព្រៃស្រោង |  |
| 8 | Code : 3400<br>ព្រៃដុះឡើងវិញ |  |

| | | |
|---|---|---|
| 9 | Code : 3410<br>ព្រៃឫស្សី |  |

## ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្ត និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងឧទ្យានជាតិបូទុមសាគរ | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ១,៣៣០,១៨ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ៧៦,៥៨ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ៤៧៤,00 |
| | ចំការបោះបង់ចោលដុះស្មៅ | ដីឯកជនរបស់រដ្ឋ | ២ |
| ២ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងព្រំប្រទល់ព្រៃសម្បទានហ្គេត | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ១៥.៧៣៦.៤៨ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ១២៦.៨៣ |
| | ព្រៃលិចទឹក | ដីឯកជនរបស់រដ្ឋ | ៤៨.១ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ១១៨.៩៩ |
| | ព្រៃគុម្ពោត | ដីឯកជនរបស់រដ្ឋ | ២៣៤.២៤ |
| | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | ដីឯកជនរបស់រដ្ឋ | ៣៣.១៩ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ១៥ |
| ៣ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងព្រំប្រទល់ព្រៃសម្បទានស៊ីវរ៉ូដ | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ១១,៣៣៩.២៦ |
| | ព្រៃចំរុះ( ស្រោង និង របោះ) | ដីឯកជនរបស់រដ្ឋ | ៥៦.២៤ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ១៤២.៣៥ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ១៥.១៦ |
| | ព្រៃគម្ពោត | ដីឯកជនរបស់រដ្ឋ | ១៥៤.៧៥ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ២៣២.២៦ |
| ៤ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងព្រំប្រទល់ព្រៃសម្បទានធីពាណិជ្ជ | | |
| | ដីលំនៅដ្ឋានភូមិ | ដីឯកជន | ២.១៣ |
| | ស្រែវស្សា | ដីឯកជន | ៣៦.៧ |
| | ចំការឈើហូបផ្លែ | ដីឯកជន | ២៧៣.៨៧ |

| | | | |
|---|---|---|---|
| | ចំការដំណាំលើដីភូមិចាស់ | ដីឯកជនរបស់រដ្ឋ | ៤.១២ |
| | ចំការស្វាយចន្ទី | ដីឯកជនរបស់រដ្ឋ | ១៤.៤៥ |
| | កសិកម្មពនេចរ | ដីឯកជនរបស់រដ្ឋ | ០.៩៥ |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ៣៧,៣៤១.៩២ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ១,០៧០.៩៥ |
| | ព្រៃលិចទឹក | ដីឯកជនរបស់រដ្ឋ | ០.៣១ |
| | ល្បាយដីព្រៃលាយដីចំការ | ដីឯកជនរបស់រដ្ឋ | ២៧១.០០ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ៧៤៣.៨៤ |
| | ចំការបោះបង់ដុះស្មៅ | ដីឯកជនរបស់រដ្ឋ | ៧០.៧៤ |
| | វាលស្មៅលិចទឹក | ដីឯកជនរបស់រដ្ឋ | ៦.១៥ |
| | ព្រៃគុម្ពោត | ដីឯកជនរបស់រដ្ឋ | ២៤៥.២៥ |
| | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | ដីឯកជនរបស់រដ្ឋ | ៣៦.២ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ៨៥.៥៥ |
| | ព្រៃកាប់ឆ្ការ | ដីឯកជនរបស់រដ្ឋ | ៨.៧៨ |
| ៥ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងតំបន់ដីសេដ្ឋកិច្ចហ្គ្រីនរិច | ដីឯកជនរបស់រដ្ឋ-ដីសាធារណៈរបស់រដ្ឋ | |
| | ដីលំនៅដ្ឋានភូមិ | ដីឯកជនរបស់រដ្ឋ | ៨.៤១ |
| | ស្រែវស្សា | ដីឯកជនរបស់រដ្ឋ | ៤៨.៦៤ |
| | កសិកម្មពនេចរ | ដីសាធារណៈរបស់រដ្ឋ | ១៣០.១៧ |
| | ព្រៃស្រោង | ដីសាធារណៈរបស់រដ្ឋ | ៧៤.៧០ |
| | ព្រៃដុះឡើងវិញ | ដីសាធារណៈរបស់រដ្ឋ | ៤៧.៨៩ |
| | ព្រៃលិចទឹក | ដីសាធារណៈរបស់រដ្ឋ | ២៦៣.៨២ |
| | ព្រៃកោងកាងស្តើង | ដីសាធារណៈរបស់រដ្ឋ | ៣១៩.១៧ |
| | វាលស្មៅ | ដីសាធារណៈរបស់រដ្ឋ | ២១៩.២០ |
| | ចំការបោះបង់ចោលដុះស្មៅ | ដីសាធារណៈរបស់រដ្ឋ | ៥១.៤៧ |
| | ព្រៃគុម្ពោត | ដីសាធារណៈរបស់រដ្ឋ | ១៥០.៧៨ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ១២.៩២ |
| | ស្រែចិញ្ចឹមបង្គា | ដីសាធារណៈរបស់រដ្ឋ | ១០.៦៤ |
| | ព្រៃកាប់ឆ្ការ | ដីសាធារណៈរបស់រដ្ឋ | ៥.៥៨ |

ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តកោះកុង

ឧបសម្ព័ន្ធ ៣

បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| **ខ្វះផ្លូវគមនាគមន៍** | -ភូមិត្រពាំងរូង<br>-ភូមិដីទំនាប<br>-ភូមិព្រៃកអង្គុញ<br>-ភូមិកោះកុងក្នុង | -លំបាកក្នុងការធ្វើដំណើរ<br>-លំបាកក្នុងការទំនាក់ទំនង<br>-ឆ្ងាយពីផ្សារ<br>-សាលារៀននៅឆ្ងាយ | -សាងសង់ផ្លូវក្រាលគ្រួសក្រហម<br>-សង់ស្ពានបេតុង<br>-លើកផ្លូវលំដីស |
| **ខ្វះស្បៀង** | -ភូមិត្រពាំងរូង<br>-ភូមិដីទំនាប<br>-ភូមិព្រៃកអង្គុញ<br>-ភូមិកោះកុងក្នុង | -ខ្វះដីធ្វើស្រែ<br>-ខ្វះឧបករណ៍កសិកម្ម<br>-ទិន្នផលស្រូវទាប<br>-គ្មានមុខរបរច្បាស់លាស់<br>-ខ្វះកំលាំងអូសទាញ<br>-កំណើនគ្រួសារ | -ស្តារដីស្រែចាស់<br>-ទិញគោក្របី<br>-ទិញគោយន្តភ្ជួរស្រែ<br>-ផ្តល់ពូជស្រូវមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម<br>-វគ្គប្រព័ន្ធកសិកម្មចំរុះ<br>-ពង្រីកផ្ទៃដីកសិកម្ម |
| **ទិន្នផលស្រូវទាប** | -ភូមិត្រពាំងរូង<br>-ភូមិដីទំនាប<br>-ភូមិព្រៃកអង្គុញ<br>-ភូមិកោះកុងក្នុង | -ដីខ្សោះជីជាតិ<br>-សត្វល្អិតបំផ្លាញ<br>-ខ្វះបច្ចេកទេសកសិកម្ម<br>-ខ្វះថ្នាំសំលាប់សត្វល្អិត | -ផ្តល់ថ្នាំសំលាប់សត្វល្អិត<br>-ផ្តល់ធុងបាញ់ថ្នាំ<br>-ផ្តល់ពូជស្រូវមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសដល់សហគមន៍(កសិកម្ម) |

| | | | |
|---|---|---|---|
| **គ្មានកសិដ្ឋានចិញ្ចឹមសត្វ** | -ភូមិត្រពាំងរូង<br>-ភូមិដីទំនាប<br>-ភូមិព្រៃកអង្គុញ<br>-ភូមិកោះកុងក្នុង | -ខ្វះទីតាំងដី<br>-ខ្វះទុន<br>-ខ្វះពូជសត្វ<br>-ខ្វះបច្ចេកទេសចិញ្ចឹមសត្វ | -បង្កើតកសិដ្ឋានចិញ្ចឹមសត្វ<br>-ផ្តល់ពូជសត្វស្រុក<br>-ផ្តល់ពូជពពៃ<br>-ជីកស្រះចិញ្ចឹមត្រីតាមគ្រួសារ<br>-ផ្តល់ពូជត្រី<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ |
| **កសិផលគ្មានទីផ្សារ** | ០៤ ភូមិ | -គ្មានទីផ្សារលក់ដូ | -បង្កើតទីផ្សារ<br>-បង្កើតសេវាម៉ាស៊ីនកិនស្រូវ |
| **ខ្វះបណ្តាញអគ្គិសនី** | ០៤ ភូមិ | -គ្មានអគ្គិសនីប្រើប្រាស់ | -តំលើងប្រព័ន្ធអគ្គិសនី<br>-ប្រព័ន្ធអគ្គិសនីប្រើពន្លឺព្រះអាទិត្យ |
| **កុមារមិនបានចូលរៀន** | ០៤ភូមិ | -ខ្វះសាលារៀន<br>-ខ្វះគ្រូបង្រៀន<br>-គ្រួសារក្រីក្រ | -សាងសង់សាលារៀន<br>-ផ្តល់គ្រូបង្រៀន<br>-បើកថ្នាក់មតេយ្យ<br>-បណ្តុះបណ្តាលគ្រូមតេយ្យក្នុងមូលដ្ឋាន<br>-បង្កើតបណ្ណាល័យ<br>-សង់អគារទីចាត់ការសាលា |
| **អក្ខរជនច្រើន** | ០៤ ភូមិ | -ជីវភាពក្រីក្រ | -បើកថ្នាក់អក្ខរកម្ម<br>-វគ្គបំប៉នបច្ចេកទេសអក្ខរកម្ម<br>-កម្មវិធីអប់រំក្រៅប្រព័ន្ធ |

| | | | |
|---|---|---|---|
| **សុខភាពម្ដាយទារក** | ០៤ ភូមិ | -ហូបមិនគ្រប់គ្រាន់<br>-ខ្វះថ្នាំព្យាបាល<br>-ខ្វះអនាម័យ<br>-ធ្វើការហួសកំលាំង<br>-ខ្វះសេវាសុខភាព | -សង់ប៉ុស្តិ៍សុខភាព<br>-សង់បង្គន់អនាម័យ<br>-អប់រំចំណេះដឹងអាហារូបត្ថម្ភ<br>-បណ្ដុះបណ្ដាលឆ្មបបុរាណ |
| **ខ្វះទឹកស្អាត** | ០៤ ភូមិ | -គ្មានអណ្ដូងលូ<br>-គ្មានអណ្ដូងស្នប់<br>-គ្មានស្រះទឹក | -ជីកអណ្ដូងលូ<br>-ជីកអណ្ដូងស្នប់<br>-ជីកស្រះទឹកធម្មតា |
| **គ្មានភ្លេងប្រពៃណី** | ០៤ ភូមិ | ឧបករណ៍តន្ត្រី | -បង្កើតវង់ភ្លេងប្រពៃណី<br>-ផ្ដល់ឧបករណ៍ភ្លេងមួយកំប្លេ<br>-បណ្ដុះបណ្ដាលតន្ត្រីបុរាណ |
| **ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី** | | -គ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់<br>-គ្មានលទ្ធភាពធ្វើប័ណ្ណ<br>-តំលៃធ្វើប័ណ្ណខ្ពស់ | -ផ្ដល់ប័ណ្ណកម្មសិទ្ធិស្របច្បាប់<br>-ផ្សព្វផ្សាយចំណេះដឹងច្បាប់ភូមិបាល<br>-ផ្សព្វផ្សាយជំរុញការងារចុះបញ្ជីដីធ្លី<br>-កំណត់តំបន់ប្រើប្រាស់ដីធ្លី<br>-កំណត់ព្រំប្រទល់រដ្ឋបាលភូមិឃុំ<br>-រៀបចំស្លាកលេខផ្ទះ<br>-រៀបចំសណ្ដាប់ធ្នាប់សំណង់លំនៅដ្ឋាន<br>-បណ្ដុះបណ្ដាលកុំព្យូទ័រដល់ស្មៀនឃុំ<br>-ពង្រីកកិច្ចការបញ្ជីអត្រានុកូលដ្ឋាន |

| | | | |
|---|---|---|---|
| **ល្បែងស៊ីសង** | ០៤ ភូមិ | -ខ្វះការបង្ក្រាប<br>-មិនគោរពច្បាប់<br>-ច្បាប់ធូរលុង<br>-អសីលធម៌ក្នុងសង្គម | -បង្កើតក្រុមបង្ក្រាបល្បែងស៊ីសង និង ក្រុមបងធំ<br>-បង្កើតកម្មវិធីមិត្តអប់រំមិត្ត<br>-ផ្សព្វផ្សាយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ<br>-ផ្សព្វផ្សាយការប្រឆាំង ការលេងល្បែងស៊ីសង<br>-ផ្សព្វផ្សាយច្បាប់រដ្ឋប្បវេណី និង ព្រហ្មទណ្ឌ |
| **ចិញ្ចឹមសត្វអនាធិបតេយ្យ** | ០៤ ភូមិ | -ខ្វះការគ្រប់គ្រង<br>-លែងសត្វឱ្យស៊ីដំណាំអ្នកដ៏ទៃ<br>គ្មានការទទួលខុសត្រូវ | -អប់រំស្តីពីការចិញ្ចឹមសត្វដោយសុវត្ថិភាព<br>-ធ្វើរបងព័ទ្ធតំបន់ចិញ្ចឹមសត្វ |
| **អាវុធជាតិផ្ទុះគ្រប់ប្រភេទ** | ០៤ ភូមិ | -ថ្មែអាវុធមិនទាន់ផ្ទុះ<br>-ថ្មែអាវុធប្រមាញ់សត្វ<br>-លួចលាក់ទុកអាវុធ និង គ្រឿងផ្ទុះ | -ផ្សព្វផ្សាយស្តីពីការប្រើប្រាស់អាវុធជាតិផ្ទុះ<br>-អប់រំការយល់ដឹងអំពីមីន និង គ្រាប់មិនទាន់ផ្ទុះ<br>-ដកហូតអាវុធជាតិផ្ទុះគ្រប់ប្រភេទ |
| **ដីខ្សោះជីជាតិ** | ០៤ ភូមិ | -ដីគ្មានជីវជាតិ<br>-ខ្វះបច្ចេកទេសកែប្រែគុណភាពដី<br>-ខ្វះជី | -បណ្តុះបណ្តាលធ្វើជីកំប៉ុស្តិ៍<br>-បណ្តុះបណ្តាលការប្រើប្រាស់ជីគ្រប់ប្រភេទ<br>-បង្កើតជំរកសត្វប្រចៀវយកអាចម៏ |
| **ធនធានជលផលថយចុះ** | ០៤ ភូមិ | -អ្នកនេសាទកើនឡើង<br>-ប្រើប្រាស់ឧបករណ៍ខុសច្បាប់<br>-ប្រើប្រាស់ថ្នាំពុល | -បង្កើតគណៈកម្មការនេសាទខុសច្បាប់<br>-បង្កើតសមាគមន៏ការពារតំបន់នេសាទ<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-អភិរក្សតំបន់ត្រីពងកូន |

| | | | |
|---|---|---|---|
| | | | -អភិរក្សត្រីនាគ<br>-ធ្វើប៉ាន់ណូផ្សព្វផ្សាយការពារធនធានជលផល |
| **បឹងរាក់** | ០៤ ភូមិ | -ការហូរច្រោះ<br>-បាត់បង់ព្រៃមាត់បឹង | -ស្តារបឹងឡើងវិញ<br>-ដាំដើមឈើជុំវិញមាត់បឹង<br>-ព័ទ្ធរបងជុំវិញបឹង |
| **បាត់បង់ព្រៃឈើ** | ០៤ ភូមិ | -កាប់ទន្ទ្រានយកដី | -ផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>-ផ្សព្វផ្សាយជំរុញការដាំកូនឈើ<br>-អប់រំចំណេះដឹងបរិស្ថាន និង ច្បាប់បរិស្ថាន<br>-អប់រំស្តីពីផលប្រយោជន៍ព្រៃឈើ<br>-កសាងប៉ាណូផ្សព្វផ្សាយបរិស្ថាន<br>-បង្កើតថ្នាលបណ្តុះបណ្តាលព្រៃឈើ<br>-អប់រំផ្សព្វផ្សាយអភិរក្សព្រៃឫស្សី<br>-ដាក់ធុងសំរាមសាធារណៈ |
| **ខ្វះថាមពលឧស្ម័ន** | ០៤ ភូមិ | -ខ្វះបច្ចេកទេសផលិតឧស្ម័នធម្មជាតិ | -បណ្តុះបណ្តាលការធ្វើឡចង្រ្កានជីវឧស្ម័ន<br>-បច្ចេកទេសធ្វើឡចង្រ្កានសន្សំអុស |
| **ប្រាក់ចំណូលថយចុះ** | ០៤ ភូមិ | -ធនធានជលផលថយចុះ<br>-ខ្វះមុខរបរ | -ធ្វើសួនបន្លែតាមគ្រួសារ<br>-បណ្តុះបណ្តាលការបណ្តុះផ្សិត<br>-បង្កើតតំបន់ទេសចរធម្មជាតិ |
| **គ្មានការងារធ្វើ** | ០៤ ភូមិ | -គ្មានមុខជំនាញ | -បង្កើតសិប្បកម្មកែច្នៃផ្តៅ ឫស្សី |

| | | | |
|---|---|---|---|
| | | -គ្មានមុខរបរ<br>-គ្មានទុន | -វគ្គជំនាញច្នៃផ្តៅ ឫស្សី<br>-បង្រៀនមុខជំនាញអ៊ុតសក់ កាត់សក់ សំអាងការ |
| **ដើមចាកថយចុះ** | ០៤ ភូមិ | -ប្រើប្រាស់ខុសបច្ចេកទេស<br>-តំរូវការប្រើប្រាស់ច្រើនឡើង<br>-ខ្វះធនធានការពារ | -ដាំចាកឡើងវិញ<br>-បង្កើតក្រុមប្រជាការពារដើមចាក |
| **អំពើហឹង្សាក្នុងគ្រួសារ** | ០៤ ភូមិ | -ជីវភាពក្រីក្រ<br>-អវិជ្ជា<br>-សេពគ្រឿងស្រវឹង<br>-រំលោភសិទ្ធិ<br>-ល្បែងស៊ីសង | -វគ្គផ្សព្វផ្សាយច្បាប់អប់រំអំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស |
| **សុខភាពផ្លូវភេទ** | ០៤ ភូមិ | -ខ្វះការយល់ដឹងអំពីការថែទាំសុខភាព<br>-ខ្វះអនាម័យពេលសំរាលកូន<br>-កូនច្រើន | -ផ្សព្វផ្សាយអំពីកាមរោគ និង ជំងឺអេដស៍<br>-ផ្សព្វផ្សាយអំពីសុខភាពបន្តពូជ<br>-ផ្សព្វផ្សាយពន្យាកំណើត<br>-បណ្តុះបណ្តាលឆ្មបភូមិ<br>-ផ្សព្វផ្សាយអំពីការប្រើស្រោមអនាម័យ<br>-ផ្សព្វផ្សាយអំពីបំនិនជីវិត<br>-បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី |
| **ស្ត្រី និង កុមាររងគ្រោះ** | ០៤ ភូមិ | -ចាញ់បោកគេ | -ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្ត្រីកុមារ |

| | | | |
|---|---|---|---|
| | | -ចាប់ជំរិត<br>-រំលោភសេពសន្ថវៈ<br>-អវិជ្ជា<br>-ក្រីក្រ<br>-កំព្រា<br>-ចំណាកស្រុក | -ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរមនុស្ស<br>-ផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ<br>-ផ្សព្វផ្សាយការប្រឆាំងការរំលោភផ្លូវភេទស្ត្រី និង កុមារ |

**ឧបសម្ព័ន្ធ ៤**

**ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត**

**កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)**

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀង នៅលើ ផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| -មានផ្លូវលំក្រាលគ្រួសក្រហម<br>-មានផ្លូវលំដីស | CDP | -ប្រជាពលរដ្ឋប្រមាណ ៧០%-៨០% មិនទទួលបាន នូវផ្លូវគមនាគមន៍ប្រើតាម រយៈការសាសង់ផ្លូវលំគ្រួស ក្រហម និង លើកផ្លូវលំដីស ដើម្បីងាយស្រួលក្នុងការធ្វើ ដំណើរ និង ចរាចរទំនិញ ផ្សេងៗ | -ជំរុញការសាងសង់ផ្លូវ លំក្រាលគ្រួសក្រហម និង ផ្លូវដីស<br>-កាត់បន្ថយការ ចំណាយទៅលើ មធ្យោបាយធ្វើដំណើរ | -សាងសង់ផ្លូវលំក្រាលគ្រួស ក្រហម<br>-សង់ស្ពានបេតុង<br>-លើកផ្លូវលំដីស | |
| -មានដីធ្វើស្រែ | CDP | បង្កើនផ្ទៃដីកសិកម្មតាមរយៈ ការស្តារដីស្រែចាស់ | - ជំរុញលើកកំពស់ការ ស្តារពង្រីកផ្ទៃដីកសិកម្ម | - ស្តារដីស្រែចាស់ | |
| មានប័ណ្ណកម្មសិទ្ធិស្របច្បាប់ | CDP | -ពង្រីកគណៈកម្មការ សុរិយោដីនិង បន្ថយន្ទការ | -ជំរុញការផ្តល់ប័ណ្ណ សំគាល់សិទ្ធិលើដីធ្លី | -ផ្តល់ប័ណ្ណសំគាល់សិទ្ធិស្របច្បាប់<br>-ផ្សព្វផ្សាយចំណេះដឹងច្បាប់ភូមិបាល | |

| | | | | | |
|---|---|---|---|---|---|
| | | ផ្សេងៗទៀតសំរាប់ដោះស្រាយទំនាស់ដីធ្លី និងទំនាស់ផ្សេងៗទៀតដើម្បីធានាឱ្យការដោះស្រាយយុត្តិធមិពិសេសការកំណត់ព្រំប្រទល់រដ្ឋបាលភូមិ ឃុំ និងតំបន់ប្រើប្រាស់ដីផ្សេងៗ រៀបចំសណ្តាប់ធ្នាប់សំណង់ស្នាក់នៅឈានទៅលប់បំបាត់ភាពអនាធិបតេយ្យផ្សេងៗ | ស្របច្បាប់<br>-លើកកំពស់ការអនុវត្តន៍ច្បាប់ដោះស្រាយទំនាស់ដីធ្លី<br>-ជំរុញការកំណត់ព្រំរដ្ឋបាលឱ្យបានត្រឹមត្រូវ<br>-ជំរុញនិង លើកកំពស់ការរៀបចំថែរក្សាសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន | -ផ្សព្វផ្សាយជំរុញការចុះបញ្ជីដីធ្លី<br>-កំណត់ព្រំប្រទល់រដ្ឋបាលភូមិឃុំ<br>-រៀបចំសណ្តាប់ធ្នាប់សំណង់លំនៅដ្ឋាន | |
| មានទីតាំងចិញ្ចឹមសត្វ | CDP | -បង្កើតឱ្យមានទីតាំងកសិដ្ឋានចិញ្ចឹមសត្វទទួលបានពូជសត្វល្អៗឆាប់ផ្តល់ផលជាអតិបរមាលើកកំពស់ និង បង្កើនចំណេះដឹងក្នុងការចិញ្ចឹមសត្វស្រុកការចិញ្ចឹមត្រីតាមរយៈការជីកស្រះចិញ្ចឹមតាមគ្រួសារ | -ជំរុញឱ្យមានកសិដ្ឋានចិញ្ចឹមសត្វ<br>-ជំរុញការជីកស្រះចិញ្ចឹមត្រី | -បង្កើតកសិដ្ឋានចិញ្ចឹមសត្វ<br>-ជីកស្រះចិញ្ចឹមត្រីតាមគ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| មានទីផ្សារ | | បង្កើតទីផ្សារលក់ផលិតផល | ជំរុញឱ្យមានទីផ្សារ | បង្កើតទីផ្សារ | |
| មានសាលារៀន | | -កាត់បន្ថយចំងាយផ្លូវ ដែលកុមារធ្វើដំណើរពីផ្ទះ មកកាន់សាលារៀននៅតាម ភូមិដាច់ស្រយាល | -ជំរុញការសាងសង់ បង្កើតសាលារៀន បឋមសិក្សា | -សាងសង់សាលារៀន | |
| -មានបង្គន់អនាម័យ<br>-មានប៉ុស្តិ៍សុខភាព | | -ប៉ុស្តិ៍សុខភាព ការផ្តល់ថ្នាំ ព្យាបាល និង ចំណេះដឹង អាហាររូបត្ថម្ភ មានបង្គន់ អនាម័យ<br>-កែលំអសេវា | -លើកកំពស់សេវាផ្តល់ ថ្នាំព្យាបាល<br>-ជំរុញឱ្យមានចំណេះ ដឹងផ្នែកអាហាររូបត្ថម្ភ | - អប់រំចំណេះដឹងអាហារូបឧត្ថម្ភ<br>-បណ្តុះបណ្តាលឆ្មបបុរាណ | |
| -មានអណ្តូងស្នប់<br>-មានអណ្តូងលូ<br>-មានស្រះទឹក<br>-មានទឹកស្អាតប្រើប្រាស់ | | -ធ្វើឱ្យប្រសើរឡើង និង បង្កើនលទ្ធិភាពប្រកបដោយ ចីរភាពក្នុងការទទួលបាន និង ប្រើប្រាស់ទឹកស្អាតតាម រយៈការជីកអណ្តូងលូ អណ្តូងស្នប់ មានស្រះទឹក ធម្មតា មានអាងស្តុកទឹកភ្លៀង | -បង្កើនការជីកណ្តូងលូ អណ្តូងស្នប់<br>-ជំរុញការជីកស្រះទឹក ធម្មតាប្រើប្រាស់<br>-ជំរុញឱ្យមានការ សាងសង់ពាង ឬអាង ស្តុកទឹក | - ជីកអណ្តូងលូ<br>-ជីកអណ្តូងស្នប់<br>-ជីកស្រះធម្មតា<br>-ផ្តល់មធ្យោបាយចំរោះទឹកស្អាត<br>-អាងស្តុកទឹក | |

**ឧបសម្ព័ន្ធ ៥**

**បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ**

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ (១) | ៥ឆ្នាំទី២ (២) | ៥ឆ្នាំទី៣ (៣) | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ | 0 | 0 | 0 | 0 | 0 | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហម | ២៥.៨០៤ | គ.ម | ១១.៦០៣ | ៨.៧៥៣ | ៥.៤៤៨ | |
| | ១.១.៣. ប្រវែងផ្លូវថ្មើរជើង | 0 | 0 | 0 | 0 | 0 | |
| | ១.១.៤. ផ្លូវរទេះ/ថ្មើរជើង | 0 | 0 | 0 | 0 | 0 | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ | 0 | 0 | 0 | 0 | 0 | |
| | ១.២.២. ប្រឡាយរង | 0 | 0 | 0 | 0 | 0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | ០១ | កន្លែង | ០១ | 0 | 0 | |
| | ១.៣.២. ចំនួនស្ពានឈើ | 0 | 0 | 0 | 0 | 0 | |
| | ១.៣.៣. ចំនួន ទ្វារទឹក | 0 | 0 | 0 | 0 | 0 | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ( លូជ្រុង) | 0 | 0 | 0 | 0 | 0 | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ០១ | អគារ | 0 | 0 | ០១ | |
| | ២.៦.១.២.៤. សាលាអនុវិទ្យាល័យ | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.២.៥. សាលាវិទ្យាល័យ | ០១ | កន្លែង | 0 | ០១ | 0 | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២,៦,១,៣,១ មណ្ឌលសុខភាព | 0 | 0 | 0 | 0 | 0 | |
| | ២,៦,១,៣,២, ប៉ុស្តិ៍សុខភាព | ០១ | កន្លែង | ០១ | 0 | 0 | |
| | ២,៦,១,៣,៣ ស្រះទឹកស្អាត | ០១ | កន្លែង | ០១ | 0 | 0 | ពង្រីកបន្ថែម |
| | ២,៦,១,៣,៤ អណ្តូងទឹកស្អាត | | | | | | |
| | ២,៦,១,៣,៥ កន្លែងចាក់សំរាម | ០១ | កន្លែង | ០១ | 0 | 0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៤.២. ទីតាំងផ្សារ | 0 | 0 | 0 | 0 | 0 | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសការៈបូជា | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥.២. វត្តអារាម | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥.៣. សាលាឆទាន | 0៣ | កន្លែង | 0១ | 0១ | 0១ | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ក្រុមហ៊ុនព្រៃសម្បទានស៊ីលវើរ៉ូដ | ១0២,៤២១.00 | | | | | នៅដដែល |
| | ២.៦.២.១.២. ក្រុមហ៊ុនព្រៃសម្បទាន ហ្គេត | ៩៥,៥00.៩៦ | | | | | លុបចោល |
| | ២.៦.២.១.៣. ក្រុមហ៊ុនព្រៃសម្បទាន ធីពាណិជ្ជ | ៧១,0១៧.២២ | | | | | លុបចោល |
| | ២.៦.២.១.៤. ឧទ្យានជាតិបូទុមសាគរ | ១,៨៨២.៨៤ | | | | | នៅដដែល |
| | ២.៦.២.១.៥. ក្រុមហ៊ុន ហ្វ្រីនិរិច | ១,៣៩៧.៤៥ | | | | | នៅដដែល |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ១១៤.៤៨ | ហិកតា | ៧២.៣៦ | ២0.៨៨ | ២១.២៤ | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | 0 | 0 | 0 | 0 | 0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.២.៣. ដីវាលស្រែ | ១៨៣.៣៨ | ហិកតា | ១២០ | ២៦.៣៨ | ៣៧ | |
| | ២.៦.២.២.៤. ដីស្រោចស្រព | 0 | 0 | 0 | 0 | 0 | |
| | ២.៦.២.២.៥. ដីចំការដំណាំហូបផ្លែ | ៣២៩.៤៥ | ហិកតា | ២២៥ | ៩២.២០ | ១០២.២៥ | |
| | ២.៦.២.២.៦. ដីសម្បទានសង្គមកិច្ច | ៨៥០ | ហិកតា | ២៨៣ | ២៨៣ | ២៨៤ | |
| | ២.៦.២.២.៧. ផ្សេងៗ | | | | | | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីការធ្វើស្រែ | | | | | | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ដី | | | | | | |
| | ២.៦.២.៣.៣. វគ្គបណ្តុះបណ្តាល អំពីការកែប្រែគុណភាពដី | | | | | | |
| | ២.៦.២.៣.៤. វគ្គបណ្តុះបណ្តាលអំពីកែច្នៃផ្តៅ ឫស្សី | | | | | | |
| | ២,៦,៣,៣,៥ ផ្សព្វផ្សាយច្បាប់ភូមិបាល រដ្ឋបាលព្រៃឈើ | | | | | | |

(១) - ៥ឆ្នាំទី១ (២០០៨-២០១២)៖ បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

(១) - ៥ឆ្នាំទី២ (២០១៣-២០១៧)៖ គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

(១) - ៥ឆ្នាំទី២ (២០១៨-២០២២)៖ គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)